# វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវ

នាយកដ្ឋានព័ត៌មាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានៃ
ព្រះរាជាណាចក្រកម្ពុជា

# លក្ខខណ្ឌ និងមុខងាររបស់សភាកម្ពុជា និង ប្រព័ន្ធគ្រប់គ្រងរដ្ឋ៖ នៅក្នុងបរិបទអន្តរជាតិ

ស្រាវជ្រាវដោយ៖ បណ្ឌិត ថែន ថេលើ
លោក មូសារ អ៊ីស្សាម
លោក នន់ អស្សាច័ន្ទ
ផ្តល់ប្រឹក្សាដោយ៖ លោក ឃុត ឥន្ទសេរី

ខែឧសភា ឆ្នាំ ២០១៧

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយ ដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


សេចក្តីសង្ខេប ..... i

១. សេចក្តីផ្តើម ..... 1

២.តួនាទីរបស់សភាក្នុងប្រទេសលទ្ធិប្រជាធិបតេយ្យ ..... 1

២.១ លទ្ធិប្រជាធិបតេយ្យជាអ្វី ? ..... 1

២.២ ហេតុអ្វីបានជាប្រទេសជាច្រើនសុទ្ធតែមានសភា ? ..... 1

២.៣ ការបែងចែកអំណាច ..... 2

២.៤. មុខងារទាំងបីរបស់សភា ..... 2

២.៥ ក្របខណ្ឌសម្រាប់សភាបែបប្រជាធិបតេយ្យ ..... 4

៣. ភាពខុសគ្នានៃប្រព័ន្ធគ្រប់គ្រងរដ្ឋ ..... 5

៣.១. តើសភានៅលើពិភពលោកមានភាពខុសគ្នាដូចម្តេច ? ..... 5

៣.២. ភាពខុសគ្នានៃប្រព័ន្ធគ្រប់គ្រងរដ្ឋ ..... 5

៣.២.១ រដ្ឋធម្មនុញ្ញប្រកាន់របបរាជានិយមដែលអំណាចព្រះមហាក្សត្រមានកម្រិត ..... 6

៣.២.២ ប្រព័ន្ធបែបសាធារណរដ្ឋប្រធានាធិបតីពេញលេញ ( Full presidential republics ) ..... 7

៣.២.៣ ប្រព័ន្ធបែបប្រធានាធិបតីមិនពេញលេញ( Semi-presidential system ) ..... 9

៤. ប្រព័ន្ធបោះឆ្នោត ..... 10

៤.១ មុខងារនៃការបោះឆ្នោត ..... 10

៤.២ តើប្រព័ន្ធបោះឆ្នោតមានភាពខុសគ្នាដូចម្តេច ? ..... 10

៤.២.១ ប្រព័ន្ធឯកត្តនាម ..... 11

៤.២.២ ប្រព័ន្ធសមាមាត្រ (រួមមានបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស) ..... 12

៤.២.៣ ប្រព័ន្ធបោះឆ្នោតពីរជុំ ..... 13

៤.២.៤ ប្រព័ន្ធបោះឆ្នោតចម្រុះ ..... 13

៤.៣. សេចក្តីសង្ខេប ..... 14

៤.៣.១ ស្ថិតិសកលទាក់ទងនឹងថវិកាសភា និងបុគ្គលិក ..... 14

៤.៣.២ សារៈសំខាន់ក្នុងការបញ្ចូលស្ត្រីឲ្យក្លាយជាសមាជិកសភា 15
៤.៣.៣ ទំនាក់ទំនងរវាង ប្រជាជន និងសភា 15
៤.៤ ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា 16
៥. សភាកម្ពុជា 18
៥.១ តើទម្រង់ និងលក្ខខណ្ឌនៃសភាកម្ពុជាមានលក្ខណៈដូចម្ដេច ? 18
៥.១.១. ប្រវត្តិនៃការបង្កើតសភាកន្លងទៅថ្មីៗនេះ 18
៥.១.២ រដ្ឋធម្មនុញ្ញ និងប្រព័ន្ធគ្រប់គ្រងរដ្ឋ 18
៥.១.៣ អំឡុងពេលនៃការពង្រឹងសភា 19
៥.១.៤ ស្ថាប័នទាំងបីរបស់រដ្ឋ 20
៥.១.៤.១. ស្ថាប័ននីតិប្រតិបត្តិ 20
៥.១.៤.២ ស្ថាប័ននីតិបញ្ញត្តិ 21
៥.១.៤.៣ ស្ថាប័នតុលាការ 22
៥.២ តើសភាកម្ពុជាបំពេញមុខងារទាំងបីដោយរបៀបណា ? 23
៥.២.១ មុខងារតំណាង 23
៥.២.២ មុខងារនីតិកម្ម 24
៥.២.៣ មុខងារត្រួតពិនិត្យ 24
៥.២.៤ លក្ខខណ្ឌ និងមុខងាររបស់គណៈកម្មការ និងក្រុមផ្សេងទៀត 24
៦. ការអភិវឌ្ឍសភាក្នុងប្រទេសកម្ពុជា 26
៦.១. តើសភាកម្ពុជាមានរបៀបការងារយ៉ាងដូចម្ដេច ដើម្បីទទួលបានប្រសិទ្ធភាព ? 26
៦.២. ទំនាក់ទំនងរវាងប្រព័ន្ធផ្សព្វផ្សាយ និងព្រឹទ្ធសភា 26
គន្ថនិទ្ទេសក៍ 28

## សេចក្ដីសង្ខេប

សភា គឺជាធាតុផ្សំមួយដ៏សំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យ។ សភាជាស្ថាប័នដែលធានាថា ទស្សនៈ យោបល់ និងកង្វល់របស់ប្រជាពលរដ្ឋម្ចាស់ឆ្នោតទាំងមូលត្រូវបានត្រិះរិះពិចារណាដោយរដ្ឋាភិបាល។ ជាងនេះទៀត រដ្ឋាភិបាលមិនអាចធ្វើច្បាប់ថ្មី ឬដំឡើងពន្ធដារ ដោយគ្មានការព្រមព្រៀងពីសមាជិកសភាដែលជាតំណាងប្រជាពលរដ្ឋ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងតាមបែបលទ្ធិប្រជាធិបតេយ្យដោយប្រជាពលរដ្ឋឡើយ។

ឯកសារនេះ មានគោលបំណងផ្ដល់នូវព័ត៌មានសង្ខេប លើទិដ្ឋភាពទូទៅនៃប្រព័ន្ធសភាកម្ពុជា ដែលទាក់ទងនឹងការបង្កើតសភា រចនាសម្ព័ន្ធ មុខងារសំខាន់ៗរបស់សភា និងនីតិវិធីក្នុងការជ្រើសតាំងសមាជិកព្រឹទ្ធសភា និងសមាជិករដ្ឋសភា។ ឯកសារនេះ ក៏ធ្វើការសិក្សាទៅលើប្រព័ន្ធបោះឆ្នោត និងប្រព័ន្ធសភាកម្ពុជា ដោយមានការប្រៀបធៀបជាមួយប្រទេសមួយចំនួនដូចជា ចក្រភពអង់គ្លេស ប្រទេសអាមេរិក និងបារាំង។

ជាទូទៅ និងក្នុងបរិបទអន្តរជាតិ ឯកសារនេះពន្យល់ពីការបែងចែកអំណាច និងការទទួលខុសត្រូវរបស់ស្ថាប័នគ្រប់គ្រងរដ្ឋដែលមានអំណាចទាំងបីពោលគឺស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ ការបែងចែកអំណាចនេះ ត្រូវធានាថាមិនមានការប្រមូលផ្ដុំអំណាចនៅក្នុងស្ថាប័នណាមួយឡើយ។ ជាទូទៅ ការបែងចែកអំណាចគឺមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសមួយ ប៉ុន្តែគោលបំណងទូទៅគឺការផ្ដល់នូវប្រព័ន្ធត្រួតពិនិត្យតុល្យភាពអំណាចក្នុងការគ្រប់គ្រងប្រទេស។ នៅក្នុងផ្នែកបន្ទាប់ ឯកសារនេះពិនិត្យមើលទៅលើមុខងារទាំងបីរបស់សភា ដែលរួមមានមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ថាតើមុខងារទាំងបីនេះទាក់ទងនឹងការងារអ្វីខ្លះ។

នៅក្នុងលក្ខខណ្ឌទូទៅ សភារបស់ប្រទេសនីមួយៗមានលក្ខណៈសម្បត្តិផ្សេងៗពីគ្នាដោយយោងទៅលើកត្តាប្រវត្តិសាស្ត្រ វប្បធម៌ និងពេលខ្លះពាក់ព័ន្ធនឹងសាសនា។ សភាពីរថ្នាក់របស់កម្ពុជាត្រូវបានបង្កើតតាំងពីឆ្នាំ ១៩៤៧ នៅពេលដែលរដ្ឋធម្មនុញ្ញកម្ពុជាដំបូងត្រូវបានអនុម័ត ប៉ុន្តែរបបសភាពីរថ្នាក់នេះត្រូវបានរំលាយនៅក្នុងឆ្នាំ១៩៧៥។ សភាកម្ពុជាបច្ចុប្បន្នមានភាពថ្មីថ្មោង ដោយសភានេះទើបត្រូវបានរៀបចំឲ្យបានប្រសើរឡើងចាប់ពីឆ្នាំ១៩៩៣ ស្របជាមួយនឹងការទទួលបានបទពិសោធន៍ពីប្រទេសជាច្រើន។ ឧទាហរណ៍ ប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់កម្ពុជាគឺ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ របបនេះមានភាពស្រដៀងនឹងចក្រភពអង់គ្លេស ប៉ុន្តែផ្ទុយនឹងសហរដ្ឋអាមេរិក ដែលជារបបសាធារណរដ្ឋប្រធានាធិបតីពេញលេញ។ រីឯបារាំងវិញ ប្រកាន់របបប្រធានាធិបតីពាក់កណ្ដាល។ ភាពខុសគ្នាទាំងនេះភាគច្រើនទាក់ទងទៅនឹងតួនាទីដែលកំណត់ថ្វាយព្រះមហាក្សត្រ ក៏ដូចជាតួនាទីរបស់ប្រធានាធិបតី និងនីតិវិធីទំនាក់ទំនងការងារក្នុងដំណើរការរបស់របបសភាពីរថ្នាក់ ឬការបែងចែកអំណាចរវាងសភាទាំងពីរថ្នាក់ (កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន ៧៤ ដែលមានរបបសភាពីរថ្នាក់)។ ចំណែកឯប្រព័ន្ធ

បោះឆ្នោតវិញក៏មានភាពខុសគ្នាដែរ។ ឧទាហរណ៍ ប្រព័ន្ធបោះឆ្នោតឯកត្តនាមរបស់ ចក្រភពអង់គ្លេស កំណត់ថាអ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេក្នុងមណ្ឌលបោះឆ្នោតណាមួយ គឺជាអ្នកឈ្នះនៅក្នុងមណ្ឌលនោះ។ ចំណែកឯកម្ពុជាវិញ ប្រើប្រាស់ប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយបែងចែកអាសនៈសភាទៅឲ្យគណបក្សមួយដោយយោងលើភាគរយសន្លឹកឆ្នោតដែលគណបក្សនោះទទួលបានពីប្រជាជនម្ចាស់ឆ្នោតទូទាំងប្រទេស។ ទោះបីជាយ៉ាងនេះក្តី មិនមានប្រព័ន្ធដឹកនាំរដ្ឋណាមួយ ដែលបង្ហាញពីលទ្ធិប្រជាធិបតេយ្យដ៏ល្អឥតខ្ចោះឡើយ បើនិយាយពីការបែងចែកអំណាច ប្រព័ន្ធអភិបាលកិច្ច ឬប្រព័ន្ធបោះឆ្នោត។

ឯកសារនេះសង្កត់ធ្ងន់ទៅលើសភាកម្ពុជា និងជាបន្តបន្ទាប់គឺនិយាយបកស្រាយពីមូលដ្ឋាននៃការបង្កើតសភាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ រួមនឹងការអភិវឌ្ឍ និងការរួបរួមរបស់កម្ពុជា ចាប់តាំងពីមានសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១។ ឯកសារនេះ រៀបរាប់អំពីតួនាទីផ្សេងគ្នារបស់រដ្ឋសភា និងព្រឹទ្ធសភា នីតិវិធីដែលសមាជិកសភាទាំងពីរត្រូវបានជ្រើសតាំង និងនីតិវិធីទំនាក់ទំនងការងាររវាងសភាទាំងពីរ។ ការបែងចែកអំណាចគ្រប់គ្រងរដ្ឋរវាងស្ថាប័ននីតិប្រតិបត្តិ ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នតុលាការ ត្រូវបានពិនិត្យតាមដានតាមរយៈការអនុវត្តមុខងារទាំងបីរបស់សភា គឺ មុខងារ នីតិកម្ម មុខងារតំណាង និងមុខងារត្រួតពិនិត្យ។ ឯកសារនេះ ក៏នឹងធ្វើការបកស្រាយលម្អិតទាក់ទងនឹងការបំពេញតួនាទីរបស់សភា ហើយថែមទាំងពិពណ៌នាអំពីគណៈកម្មការនានា និងក្រុមផ្សេងៗរបស់សភា ដែលធ្វើការពាក់ព័ន្ធនឹងបញ្ហាជាក់លាក់មួយចំនួន ក៏ដូចកិច្ចទំនាក់ទំនងអន្តរជាតិ។ ឯកសារនេះ បញ្ចប់សេចក្តីដោយការគូសបញ្ជាក់ពីរបៀបដែលព្រឹទ្ធសភាជំរុញឲ្យការប្រាស្រ័យឆ្លើយឆ្លងជាមួយម្ចាស់ឆ្នោត និងប្រជាពលរដ្ឋនៅតាមភូមិភាគទាំង ៨ នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដើម្បីឲ្យម្ចាស់ឆ្នោត (ក្រុមប្រឹក្សាឃុំ សង្កាត់) និងប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនពីការងារសភា និងជួយជំរុញឲ្យការអនុវត្តមុខងារតំណាងរបស់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរ។

## ១. សេចក្តីផ្តើម

ឯកសារនេះមានគោលបំណងផ្តល់ព័ត៌មានសង្ខេប ប៉ុន្តែមានការពន្យល់នូវខ្លឹមសារសំខាន់ៗទាក់ទងនឹងស្ថាប័នរដ្ឋ និងប្រព័ន្ធសភាកម្ពុជា។ ឯកសារនេះ ពន្យល់ពីមូលហេតុនៃការបង្កើតសភា តួនាទីសភា រចនាសម្ព័ន្ធ និងនីតិវិធីក្នុងការជ្រើសរើសសមាជិកព្រឹទ្ធសភា ក៏ដូចជាសមាជិករដ្ឋសភា។ ឯកសារនេះ ក៏មានការពិនិត្យមើលប្រទេសកម្ពុជាទៅក្នុងបរិបទអន្តរជាតិ ដោយធ្វើការប្រៀបធៀបដំណើរការសភា និងប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសមួយចំនួន ដូចជាចក្រភពអង់គ្លេស សហរដ្ឋ អាមេរិក និងបារាំង។ ផ្នែកចុងក្រោយនៃឯកសារនេះ ពិនិត្យលើដំណើរវិវឌ្ឍន៍របស់សភាកម្ពុជា និងចំណុចគោលដៅសម្រាប់អភិវឌ្ឍន៍។ ចំណុចចុងក្រោយបង្អស់ ឯកសារនេះផ្តល់ព័ត៌មានសង្ខេបដល់សមាជិកសភាថ្មី បុគ្គលិកសភា និងមន្ត្រីពាក់ព័ន្ធជាច្រើនទៀតឲ្យបានយល់ស៊ីជម្រៅចំពោះបរិបទការងារដែលត្រូវបំពេញ។

## ២.តួនាទីរបស់សភាក្នុងប្រទេសលទ្ធិប្រជាធិបតេយ្យ

### *២.១ លទ្ធិប្រជាធិបតេយ្យជាអ្វី?*

ប្រធានាធិបតីអាមេរិក អាប្រាហាម លីងខិន បានឲ្យនិយមន័យពាក្យ "លទ្ធិប្រជាធិបតេយ្យ" ថាជា " ប្រព័ន្ធគ្រប់គ្រងរបស់ប្រជាពលរដ្ឋ បង្កើតដោយប្រជាពលរដ្ឋ សម្រាប់ប្រជាពលរដ្ឋ" ។ កាន់តែច្បាស់ជាងនេះទៀត សមាសភាពសំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ រួមមាន៖ សិទ្ធិប្រជាពលរដ្ឋក្នុងការជ្រើសរើសអ្នកបង្កើតគោលនយោបាយតាមរយៈការបោះឆ្នោត សិទ្ធិស្មើភាពគ្នាក្នុងការបោះឆ្នោត ជម្រើសបេក្ខភាព សេរីភាពក្នុងការសម្រេចចិត្ត និងការផ្តល់អាទិភាពចំពោះសំឡេងភាគច្រើន ដោយមិនគោរពចំពោះភាគតិច។[1] ទោះបីថាប្រទេសនៅលើពិភពលោកមានទស្សនៈផ្សេងៗគ្នាទៅលើនិយមន័យពាក្យលទ្ធិប្រជាធិបតេយ្យ និងទៅលើការផ្តល់សេរីភាពក្តី ជាតុផ្សំនៃលទ្ធិប្រជាធិបតេយ្យដែលលើកយកមកសរសេរទាំងនេះ ពិតជាមានសារៈសំខាន់ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ក៏ដូចជាក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់កម្ពុជា។

### *២.២ ហេតុអ្វីបានជាប្រទេសជាច្រើនសុទ្ធតែមានសភា?*

សភាគឺជាសមាសធាតុដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងលទ្ធិប្រជាធិបតេយ្យ។ លទ្ធិប្រជាធិបតេយ្យតម្រូវឲ្យមានសភា ក៏ប៉ុន្តែការមានសភាមិនប្រាកដថាមានលទ្ធិប្រជាធិបតេយ្យទេ។[2] សភាជាតួអង្គដ៏ចាំបាច់ក្នុងការធានាថា ការបង្ហាញទស្សនៈ និងកង្វល់របស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោតត្រូវបានយកមកពិចារណាដោយរដ្ឋាភិបាល ហើយរដ្ឋាភិបាល មិនអាចធ្វើច្បាប់ថ្មី ឬក៏បង្កើនពន្ធផ្សេងៗ ដោយគ្មានការព្រមព្រៀងពីសមាជិកសភាឡើយ។ ពិតណាស់ ភាពរីកចម្រើននៃបច្ចេកវិទ្យាទំនាក់ទំនង និងការកើនឡើងនៃប្រព័ន្ធផ្សព្វផ្សាយព្រឹត្តិការណ៍នយោបាយ បាននិងកំពុងធ្វើឲ្យសាធារណៈជនមើលឃើញកាន់តែច្រើននូវដំណើរការសភា និងអ្នកនយោបាយ ព្រមទាំងធ្វើឲ្យប្រជាជនមានការរំពឹងចំពោះសមិទ្ធផល

ដែលអ្នកនយោបាយអាចផ្តល់ជូនប្រជាពលរដ្ឋ។ ប៉ុន្តែការរំពឹងចំពោះសមិទ្ធផលទាំងអស់នេះ មិនមែនសុទ្ធតែអាចសម្រេចដូចបំណងនោះទេ។[2]

ទោះជាយ៉ាងណាក្តី មិនមែនម្ចាស់ឆ្នោតទាំងអស់សុទ្ធតែអាចបញ្ចេញមតិក្នុងការសម្រេចចិត្តនានាទាក់ទងនឹងអភិបាលកិច្ចរបស់ប្រទេសពួកគេឡើយ ទោះបីជាមានការធ្វើប្រជាមតិដែលជាឱកាសក្នុងការបញ្ចេញមតិដោយផ្ទាល់តាមបែបលទ្ធិប្រជាធិបតេយ្យផ្ទាល់ (direct democracy) ក៏ដោយ។ ដូច្នេះ ប្រព័ន្ធបោះឆ្នោតធ្វើឲ្យប្រជាជនម្ចាស់ឆ្នោតអាចជ្រើសរើសអ្នកតំណាងរបស់ខ្លួន តាមបែបលទ្ធិ-ប្រជាធិបតេយ្យដោយមានអ្នកតំណាង (representative democracy)។ អ្នកដែលត្រូវបានជ្រើសរើសដោយប្រជាជនត្រូវក្លាយជាសមាជិកសភា។

## *២.៣ ការបែងចែកអំណាច*

ការបែងចែកអំណាច មានន័យថាជាការចែករំលែកការទទួលខុសត្រូវការងារគ្រប់គ្រងរដ្ឋទៅឲ្យស្ថាប័នដាច់ដោយឡែកពីគ្នា ដើម្បីធានាថាអំណាចក្នុងលទ្ធិប្រជាធិបតេយ្យមិនត្រូវបានប្រមូលផ្តុំនៅក្នុងស្ថាប័នណាមួយ និងបង្កលក្ខណៈឲ្យមានការត្រួតពិនិត្យ និងតុល្យភាព ក្នុងការគ្រប់គ្រងដឹកនាំប្រទេស។ ការសម្រេចនានារបស់រដ្ឋ ត្រូវធ្វើឡើងតាមកម្រិតឋានានុក្រមដែលមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងធ្វើឡើងដោយ ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ដែលធ្វើសហប្រតិបត្តិការជាមួយគ្នា។ សហប្រតិបត្តិការនេះ ភាគច្រើនចែងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ ( ប៉ុន្តែមិនមែនមានចែងក្នុងគ្រប់រដ្ឋធម្មនុញ្ញទេ)។[3] ស្ថាប័ននីតិប្រតិបត្តិ មានប្រធានាធិបតី នាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី ដែលមានអំណាចច្រើនក្នុងផ្នែកនយោបាយ ប៉ុន្តែពួកគាត់ត្រូវមានការទទួលខុសត្រូវចំពោះមុខអ្នកតំណាងស្ថាប័ននីតិប្បញ្ញត្តិ។ ទ្វិសភាកម្ពុជា ព្រឹទ្ធសភា និងរដ្ឋសភា គឺជាអ្នកស្នើ ពិនិត្យច្បាប់ និងពិភាក្សាវែកញែកទៅលើច្បាប់ទាំងពួង។ ចំណែកឯស្ថាប័នតុលាការវិញ មានតួនាទីឈានមុខក្នុងការការពារ គាំទ្រច្បាប់នានា ក៏ដូចជារដ្ឋធម្មនុញ្ញ (ជាឧទាហរណ៍ ចក្រភពអង់គ្លេស ពុំមាន រដ្ឋធម្មនុញ្ញដែលសរសេរជាលាយលក្ខណ៍អក្សរឡើយ ប៉ុន្តែស្ថាប័នតុលាការរបស់ចក្រភពនេះធានាថា ច្បាប់នានាត្រូវបានយកមកបកស្រាយ និងប្រើប្រាស់ត្រឹមត្រូវ។)[4]

## *២.៤. មុខងារទាំងបីរបស់សភា*

ផ្នែកបន្ទាប់នេះ នឹងបកស្រាយពីមុខងារទាំងបីរបស់សភា។ ទោះបីបណ្តាសភានៅលើពិភពលោកមានភាពខុសគ្នាចំពោះទំហំរបៀបនៃការជ្រើសរើសសមាជិកសភា របៀបនៃការភ្ជាប់ខ្លួនរបស់សមាជិកសភាជាមួយគណបក្សនយោបាយ របៀបនៃទំនាក់ទំនងរបស់សមាជិកសភាជាមួយ ស្ថាប័ននីតិប្រតិបត្តិ ការដើរតួនាទីក្នុងការតាក់តែងច្បាប់ ការអនុម័តថវិកា និងការងារផ្សេងៗទៀតយ៉ាងណាក្តី សភាទាំងអស់សុទ្ធតែមានមុខងារសំខាន់ៗចំនួនបី[3]៖

## មុខងារតំណាង

ក្នុងមុខងារតំណាង សមាជិកសភាភ្ជាប់ខ្លួនជាមួយប្រជាពលរដ្ឋដើម្បី៖

- ធានាថាសុខទុក្ខ សំណើទាំងឡាយ ត្រូវបានឆ្លើយតបតាមរយៈដំណើរការអភិបាលកិច្ច ( ជាពិសេសនៅក្នុងការតាក់តែងច្បាប់ )
- ឲ្យប្រជាពលរដ្ឋមានទំនុកចិត្តចំពោះសភាដែលគិតពីផលប្រយោជន៍ពលរដ្ឋឲ្យបានច្រើនបំផុត។

ក្នុងលទ្ធិប្រជាធិបតេយ្យ សមាជិកសភាជាតំណាងចម្បងឲ្យប្រជាពលរដ្ឋ។ ពិតណាស់ តាមរយៈការស្ទាបស្ទង់មតិរបស់អង្គការមតិសាធារណៈពិភពលោក (World Public Opinion) ឆ្នាំ ២០០៨[5] បានបង្ហាញថា ៨៥ភាគរយនៃប្រជាជនដែលត្រូវបានសាកសួរបាននិយាយថា "ឆន្ទៈរបស់ប្រជាពលរដ្ឋគួរតែជាមូលដ្ឋានអំណាចសម្រាប់ការគ្រប់គ្រងរដ្ឋ "ដូច្នេះ" មុខងារតំណាង" គឺជាមុខងារដ៏ចម្បងមួយ។ ពិតណាស់កម្រិតនៃមុខងារតំណាងឲ្យប្រជាពលរដ្ឋរបស់សភានីមួយៗ មានភាពខុសគ្នារវាងប្រទេសនីមួយៗ។ ជាឧទាហរណ៍ ប្រទេសវៀតណាមដែលយកលំនាំតាមប្រទេសសូវៀត មានការប្រជុំសភាតិច និងមានកម្រិត ចំណែកឯអាជ្ញាធរ និងច្បាប់នានាកើតចេញពីបក្សកុម្មុយនីស ដូច្នេះហើយទើបមានយន្តការតិចតួចដែលអាចឲ្យប្រជាជនបញ្ចេញមតិ។[2] ផ្ទុយទៅវិញ នៅប្រទេសស្វីស(Switzerland)មានការធ្វើប្រជាមតិជា ទៀងទាត់ ដែលបង្ហាញពីការសង្កត់ធ្ងន់ទៅលើការព្រមព្រៀងជាលក្ខណៈជាតិ (National consensus) និងការសម្របសម្រួល។ ទិដ្ឋភាពទាំងនេះស្តែងឲ្យឃើញពីរបបបែបលទ្ធិប្រជាធិបតេយ្យផ្ទាល់ (direct democracy)។[6]

## មុខងារនីតិកម្ម

សមាជិកសភាក៏ត្រូវទទួលខុសត្រូវក្នុងការសរសេរច្បាប់ និងជាពិសេសត្រូវធានាថាច្បាប់ទាំងនេះឆ្លុះបញ្ចាំងពីទស្សនៈប្រជាពលរដ្ឋ មានភាពយុត្តិធម៌ និងសមធម៌ច្រើន (just and equitable) និងការរៀបចំច្បាប់ឲ្យត្រូវតាមគោលដៅ។ សមាជិកសភា ត្រូវធានាឲ្យការតាក់តែងច្បាប់មានលក្ខណៈលម្អិតគ្រប់ជ្រុងជ្រោយ ដោយការធ្វើសំណើច្បាប់ ឬវិសោធនកម្មច្បាប់ ដែលមានការពិភាក្សាផ្លាស់ប្តូរគំនិតយោបល់ ឬឲ្យអ្នកជំនាញធ្វើការពិនិត្យ ហើយចុងក្រោយបំផុតគឺធ្វើការបោះឆ្នោត។ នៅក្នុងប្រទេសប្រជាធិបតេយ្យ (ដូចជាកម្ពុជា) ដែលមានរបបទ្វីសភា ច្បាប់ត្រូវបានអនុម័តក្រោយពីការពិភាក្សាផ្លាស់ប្តូរគំនិតយោបល់ និងត្រូវបោះឆ្នោតនៅក្នុងសភាទាំងពីរ ដើម្បីធានាកុំឲ្យមានការមើលរំលងបញ្ហា ណាមួយ។

## មុខងារត្រួតពិនិត្យ

ដោយសារតែការបែងចែកអំណាច មុខងារទី៣នេះរបស់ស្ថាប័ននីតិប្បញ្ញត្តិ (ឬហៅថា សភា) គឺពិនិត្យមើលទៅលើការចំណាយ និងដំណើរការការងាររបស់រដ្ឋាភិបាល (ស្ថាប័ននីតិប្រតិបត្តិ) ដើម្បីធានាថាកម្មវិធីផ្សេងៗរបស់រដ្ឋាភិបាល ត្រូវបានអនុវត្តត្រឹមត្រូវ និងមានប្រសិទ្ធភាព និងផ្តល់ផលប្រយោជន៍ទៅដល់ប្រជាជនច្រើនបំផុត។ ប៉ុន្តែដំណើរការ និងអំណាចរបស់សភានានាទូទាំងពិភពលោកក្នុងការបំពេញមុខងារត្រួតពិនិត្យនេះមានភាពខុសប្លែកគ្នា ពីប្រទេសមួយទៅប្រទេសមួយ ដូចជាកម្រិត

នៃការបែងចែកអំណាចរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិប្បញ្ញត្តិពីប្រទេសមួយទៅប្រទេសមួយដែរ (ការបកស្រាយបន្ថែមនឹងធ្វើឡើងនៅផ្នែកបន្ទាប់)។ ទោះបីយ៉ាងនេះក្តី គ្រប់ស្ថាប័ននីតិប្បញ្ញត្តិទូទាំងពិភពលោក សុទ្ធតែមានការទទួលខុសត្រូវ ជាទូទៅចំពោះមុខងារការត្រួតពិនិត្យនេះ ដោយស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងរដ្ឋដែលមានការត្រួតពិនិត្យនិងតុល្យភាពរវាងអំណាច និងអំណាច (check and balance of powers)។[7]

របាយការណ៍សភាសាកលបានសរសេរថា ប្រជាជនក្នុងប្រទេសជាច្រើនក្នុងពិភពលោកលើកជាសំណួរថា តើសភារបស់ពួកគេមានប្រសិទ្ធភាពកម្រិតណាក្នុងការធ្វើឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។[2] ទន្ទឹមនឹងនេះ ការអនុវត្តមុខងារត្រួតពិនិត្យរបស់សភានានាមានកាន់តែច្រើនឡើងដោយសារសកម្មភាពរដ្ឋាភិបាលរបស់ពួកគេមានកាន់តែធំទៅៗ។

## *២.៥ ក្របខណ្ឌសម្រាប់សភាបែបប្រជាធិបតេយ្យ*

ភ្ជាប់ជាមួយនឹងតួនាទី និងមុខងាររបស់សភាក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបែបប្រជាធិបតេយ្យ សហភាពអន្តរសភា (Inter-Parliamentary Union)[8] គូសបញ្ជាក់ពីលក្ខណៈសម្បត្តិមួយចំនួនដែលសភាគួរតែមាន៖

- ភាពជាតំណាង៖ លក្ខណៈសម្បត្តិនេះ តម្រូវឲ្យសមាជិកសភាជាអ្នកតំណាងឲ្យប្រជាពលរដ្ឋទាំងអស់ ដូចជាប្រជាពលរដ្ឋទាំងក្នុងសង្គម និងឆាកនយោបាយជាដើម និងក្នុងទិដ្ឋភាពផ្សេងៗទៀត ដើម្បីជានាការផ្តល់ឱកាសស្មើគ្នាសម្រាប់ប្រជាពលរដ្ឋ និងការការពារសមាជិកសភាទាំងអស់ឲ្យទទួលបានសិទ្ធិស្មើៗគ្នា។
- តម្លាភាព៖ ជាការធ្វើការដោយបើកចំហ អនុញ្ញាតឲ្យមានប្រព័ន្ធផ្សព្វផ្សាយច្រើនតាមដែលអាចធ្វើទៅបាន។
- ភាពជិតស្និទ្ធ (accessible)៖ ជាការផ្តល់លទ្ធភាពឲ្យប្រជាជនគ្រប់ជាន់ថ្នាក់ទាំងអស់អាចចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សភា។
- ការទទួលខុសត្រូវរបស់សមាជិកសភា សម្រាប់រាល់សកម្មភាពរបស់ខ្លួនក្នុងនាមជាសមាជិកសភា ហើយទន្ទឹមនឹងនេះ សមាជិកសភាក៏ត្រូវប្រកាន់ខ្ជាប់សុច្ចរិតភាពដែរ។
- ប្រសិទ្ធភាព៖ លក្ខណៈសម្បត្តិនេះ តម្រូវឲ្យសមាជិកសភាបង្ហាញពីតម្លៃនៃប្រជាធិបតេយ្យ ហើយអនុវត្តមុខងារនីតិកម្ម និងត្រួតពិនិត្យរបស់ខ្លួនដើម្បីបម្រើតម្រូវការរបស់ប្រជាជនទាំងមូល។

## ៣. ភាពខុសគ្នានៃប្រព័ន្ធគ្រប់គ្រងរដ្ឋ

### *៣.១. តើសភានៅលើពិភពលោកមានភាពខុសគ្នាដូចម្ដេច?*

របាយការណ៍ឆ្នាំ ២០១២ បានបង្ហាញថា ប្រទេសចំនួន ១៩០ ក្នុងចំណោមប្រទេសចំនួន ១៩៣ មានប្រភេទសភាផ្សេងៗពីគ្នា។[2] ការបកស្រាយខាងលើពីក្របខណ្ឌទូទៅនៃសភា អាចនាំឲ្យយល់ឃើញថា សភានីមួយៗមានភាពខុសៗគ្នា ហើយសភានីមួយៗនោះ ឆ្លុះបញ្ចាំងពីបរិបទជាតិ ដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ និងពេលខ្លះទាក់ទងនឹងសាសនា។ ជាងនេះទៅទៀត បណ្ដាសភាជាច្រើនកើតចេញពីដំណើរបដិវត្តន៍ដែលបានកើតឡើងក្នុងពេលជាច្រើនសតវត្សរ៍ ដែលបណ្ដាលឲ្យសភានីមួយៗមានរបៀបរបប និងប្រពៃណីផ្សេងៗពីគ្នា។ ឧទាហរណ៍ សភាពីរថ្នាក់របស់កម្ពុជាត្រូវបានបង្កើតចាប់ពីឆ្នាំ ១៩៤៧ ប៉ុន្តែប្រព័ន្ធសភានេះត្រូវរំលាយទៅវិញក្នុងឆ្នាំ ១៩៧៥។ រដ្ឋសភាជាតិកម្ពុជាបច្ចុប្បន្នត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ នៅពេលដែលរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត និងព្រឹទ្ធសភាត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៩។ ចំណែកឯ សភាប្រទេសអ៊ីសឡង់ (Iceland's Althing) ត្រូវបានបង្កើតតាំងពីឆ្នាំ ៩៣០[9] និងសភាចក្រភពអង់គ្លេសត្រូវបានបង្កើតតាំងពីសតវត្សរ៍ទី១១មកម្ល៉េះ។[10] ជាច្រើនសតវត្សរ៍មកហើយ សមាសភាព ប្រពៃណី និងការអនុវត្តរបស់សភាជំនាន់មុន បានទទួលឥទ្ធិពលពីលក្ខខណ្ឌនៃអ្នកដែលអាចបោះឆ្នោតបាន ។ ជាឧទាហរណ៍ នៅចក្រភពអង់គ្លេស មុនឆ្នាំ ១៨៣២ មានតែបុរសដែលមានអាយុលើសពី ២១ឆ្នាំ និងមានទ្រព្យសម្បត្តិច្រើនប៉ុណ្ណោះ ទើបអាចបោះឆ្នោតបាន។ ចំពោះស្ត្រី និងមនុស្សធម្មតាពិសេសអ្នកក្រ និងស្ថិតក្នុងវណ្ណៈកម្មករ មិនអាចបោះឆ្នោតបានឡើយ។ នាពេលក្រោយមកទើបមានការកើនឡើងនៃចំនួនអ្នកបោះឆ្នោតបន្តិចម្ដងៗហើយចំណែកឯស្ត្រីធម្មតាវិញមិនអាចបោះឆ្នោតបាន រហូតទាល់តែមានការបង្កើតច្បាប់ Equal Franchise Act នៅឆ្នាំ ១៩២៨។[11]

### *៣.២. ភាពខុសគ្នានៃប្រព័ន្ធគ្រប់គ្រងរដ្ឋ*

ការកំណត់នូវភាពខុសគ្នានៃប្រព័ន្ធគ្រប់គ្រងរដ្ឋនៅទូទាំងពិភពលោកអាចមានការលំបាក ដូចមានក្នុងឧទាហរណ៍ខាងលើ តើកត្តាដែលអាចឲ្យយើងយល់ពីលក្ខណៈខុសគ្នានៃលទ្ធិប្រជាធិបតេយ្យមានអ្វីខ្លះ? ឧទាហរណ៍ ប្រទេសមួយចំនួន ដែលហៅខ្លួនឯងថា សាធារណរដ្ឋប្រជាធិបតេយ្យ មានដូចជា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ អេត្យូពី និង កូរ៉េខាងជើង (Democratic Republic of the Congo, Ethiopia and North Korea) មិនបានបកស្រាយឲ្យបានច្បាស់ចំពោះពាក្យ ប្រជាធិបតេយ្យ ឬសាធារណរដ្ឋឡើយ ដោយសារប្រទេសទាំងនេះហាក់ដូចជាប្រើប្រាស់ ប្រព័ន្ធរដ្ឋឯកបក្ស ក្នុងការគ្រប់គ្រងរដ្ឋ។ ពិតណាស់ តាមរយៈសន្ទស្សន៍សេដ្ឋកិច្ចប្រជាធិបតេយ្យ (economist democracy index) ឆ្នាំ ២០១៥ ប្រទេសកុងហ្គោជាប់ចំណាត់ថ្នាក់ទី១២៣ អេត្យូពី ទី ១៤៤ និងកូរ៉េខាងជើងទី ១៦៧។[12] នេះគឺគ្រាន់តែជាឧទាហរណ៍សម្រាប់ធ្វើការប្រៀបធៀបសាមញ្ញប៉ុណ្ណោះ ពីប្រព័ន្ធគ្រប់គ្រងរដ្ឋនៅក្នុង ឯកសារនេះ។[13]

### ៣.២.១ រដ្ឋធម្មនុញ្ញប្រកាន់របបរាជានិយមដែលអំណាចព្រះមហាក្សត្រមានកម្រិត

បណ្ដាប្រទេសដែលអនុវត្តប្រព័ន្ធនេះ ជារបបរាជានិយម ដែលសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ព្រះមហាក្សត្រ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់។ ប្រទេសកម្ពុជា ប្រកាន់របបរាជានិយម ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដោយព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។ ព្រះមហាក្សត្រ ទ្រង់ជាប្រមុខរដ្ឋមួយជីវិត ព្រះអង្គជានិមិត្តរូបនៃឯកភាពជាតិ និរន្តរភាពជាតិ និងមានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្ដាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា(អំណាចនីតិប្បញ្ញត្តិ) រាជរដ្ឋាភិបាល (អំណាចនីតិប្រតិបត្តិ) ដែលមាននាយករដ្ឋមន្ត្រីជាប្រមុខ និងសាលាជម្រះក្ដី (អំណាចតុលាការ)។ ប្រព័ន្ធនេះ ក៏ត្រូវប្រើប្រាស់នៅចក្រភពអង់គ្លេសដែរ បើទោះបីថា ប្រទេសនេះពុំមានការតាក់តែងរដ្ឋធម្មនុញ្ញដោយការសរសេរក្ដី។ ប្រព័ន្ធនេះ ខុសពីប្រព័ន្ធរាជានិយមដែលអំណាចព្រះមហាក្សត្រមិនមានកម្រិត (absolute monarchy) ដូចជានៅក្នុងប្រទេស អារ៉ាប៊ីសាអូឌីត (Saudi Arabia) ឬប្រទេសព្រុយណេ (Brunei) ដែលព្រះមហាក្សត្រ ស្ថិតនៅលើច្បាប់ សូម្បីច្បាប់រដ្ឋធម្មនុញ្ញ និងមិនអាចមានមតិជំទាស់ទ្រង់ឡើយ។

#### ករណីសិក្សា៖ ចក្រភពអង់គ្លេស

នៅចក្រភពអង់គ្លេស ព្រះមហាក្សត្រ ជាព្រះប្រមុខរដ្ឋដែលមានតួនាទីត្រឹមតែជានិមិត្តរូបស្របតាមប្រពៃណី (ceremonial role) ។ នាយករដ្ឋមន្ត្រី ជាប្រធានដឹកនាំរដ្ឋាភិបាលចក្រភពអង់គ្លេស និងត្រូវទទួលខុសត្រូវចំពោះគោលនយោបាយ និងសេចក្ដីសម្រេចផ្សេងៗរបស់រដ្ឋាភិបាល។នាយករដ្ឋមន្ត្រីជាសមាជិកសភា ដែលត្រូវបានជ្រើសរើសដោយសារ លោកគឺជាមេបក្សនយោបាយដែលមានសមាជិកសភាភាគច្រើន។ នាយករដ្ឋមន្ត្រីជាប្រធានគណៈរដ្ឋមន្ត្រី មានសិទ្ធិជ្រើសរើសសមាជិកសភាមួយចំនួនឲ្យធ្វើជារដ្ឋមន្ត្រី។ នេះមានន័យថា ស្ថាប័ននីតិប្រតិបត្តិ និងនីតិប្បញ្ញត្តិរបស់ចក្រភពអង់គ្លេសមានទំនាក់ទំនងយ៉ាងជិតស្និត។

ចក្រភពនេះមានទ្វីសភា។ រដ្ឋសភា (House of Commons) ដែលមានអំណាចច្រើនជាងព្រឹទ្ធសភា មានសមាជិក ៦៥០រូប ត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាជន និងកាន់តំណែងរយៈពេល ៥ឆ្នាំ។ ព្រឹទ្ធសភា ( The House of Lords) មានអំណាចតិចជាង រដ្ឋសភា និងជាអ្នកជួយត្រួតពិនិត្យច្បាប់ដែលបានអនុម័តដោយរដ្ឋសភា។ ក្នុងការពិនិត្យឲ្យយោបល់ច្បាប់ ព្រឹទ្ធសភាមានអំណាចមួយផង ក្នុងការបដិសេធច្បាប់ដែលបានអនុម័តដោយរដ្ឋសភា ហើយមិនអាចបដិសេធច្បាប់ដែលអនុម័តដោយរដ្ឋសភាជាលើកទីពីរឡើយនៅក្នុងដំណើរការអនុម័តច្បាប់។ ចំនួនសមាជិកព្រឹទ្ធសភាមិនត្រូវបានកំណត់ឡើយ ហើយសមាជិកព្រឹទ្ធសភាក៏មិនត្រូវបានជ្រើសរើសតាមការបោះឆ្នោតពីប្រជាជនដែរ។ បច្ចុប្បន្ននេះ មុខតំណែងជាសមាជិកព្រឹទ្ធសភា មិនមែនធ្វើឡើងតាមការផ្ទេរតំណែងទៅឲ្យបងប្អូនសាច់ញាតិទេ (ដូចធ្លាប់មានកាលពីមុន) ប៉ុន្តែសមាជិកព្រឹទ្ធសភាកាន់តំណែងមួយជីវិត និងត្រូវ

តែងតាំងដោយព្រះមហាក្សត្រដោយមានការស្នើសុំពីរដ្ឋាភិបាល។ សមាជិកព្រឹទ្ធសភាមិនអាចផ្ទេរតំណែងទៅឲ្យ កូនៗរបស់ពួកគេឡើយ។ សមាជិកព្រឹទ្ធជាទូទៅ គឺជាបុគ្គលដែលមានការទទួលស្គាល់ថាមានស្នាដៃ ណាមួយ និងត្រូវបានជ្រើសចេញពីវិស័យអប់រំ សុខាភិបាល គោលនយោបាយសង្គម ឬជាអ្នកតំណាងមកពីព្រះវិហារអង់គ្លេស (the Church of England) ឬជាបុគ្គលណាមួយដែលបានចូលរួមចំណែកដ៏ច្រើនសម្រាប់ផលប្រយោជន៍ជាតិ។

ជាច្រើនសតវត្សមកហើយ ព្រឹទ្ធសភារ៉ាប់រងទទួលខុសត្រូវ ចំពោះស្ថាប័នតុលាការ ។ នេះមានន័យថា ពុំមានការបែងចែកអំណាចឲ្យបានច្បាស់លាស់ឡើយ រវាងស្ថាប័នតុលាការ និងស្ថាប័ននីតិប្បញ្ញត្តិ។ ទោះបីយ៉ាងនេះក្តី នៅឆ្នាំ ២០០៩ អំណាចតុលាការដែលធ្លាប់បានគ្រប់គ្រងដោយព្រឹទ្ធសភាត្រូវបានផ្ទេរទៅឲ្យតុលាការកំពូល។[14]

សភាចក្រភពអង់គ្លេសស្ថិតនៅក្នុងទីក្រុងឡុង ប៉ុន្តែដោយសារចក្រភពនេះមានប្រទេសចំនួន ៤ ដូច្នេះហើយ ចក្រភពនេះមាន រដ្ឋបាលសភាដាច់ដោយឡែកចំនួន៣។ សភាប្រទេសស្កុតលែន មានអំណាចធ្វើច្បាប់ពាក់ព័ន្ធនឹងបញ្ហាផ្សេងៗ ដោយមិនចាំបាច់ពិភាក្សាជាមួយសភាចក្រភពអង់គ្លេស និងមានអំណាចក្នុងការប្រមូលពន្ធមួយចំនួន។ សភាប្រទេសវែល (Wales) មានអំណាចតិចជាងសភាស្កុតលែន និងមិនអាចផ្លាស់ប្តូរការបង់ពន្ធ ឬធ្វើវិសោធនកម្មលើច្បាប់ណាមួយឡើយ។ ខុសពីប្រទេសស្កុតឡែន និងអៀរឡង់ខាងជើង (Northern Ireland) ប្រទេសវែល (Wales) ប្រើប្រាស់ច្បាប់រួមគ្នាជាមួយប្រទេសអង់គ្លេស (England)។ ចំណែកឯ សភាប្រទេសអៀរឡង់ខាងជើង (Northern Ireland) មានអំណាចមួយចំនួនក្នុងការធ្វើច្បាប់ ប៉ុន្តែមិនមានអំណាចក្នុងការកែប្រែពន្ធឡើយ។

### *៣.២.២ ប្រព័ន្ធបែបសាធារណរដ្ឋប្រធានាធិបតីពេញលេញ (Full presidential republics)*

ក្នុងប្រព័ន្ធប្រធានាធិបតី ប្រមុខរដ្ឋាភិបាលគឺជាប្រមុខរដ្ឋ។ ប្រធានាធិបតីមានអំណាចដឹកនាំស្ថាប័ននីតិប្រតិបត្តិដាច់ដោយឡែកពីស្ថាប័ននីតិប្បញ្ញត្តិ និងមិនទទួលខុសត្រូវចំពោះមុខសភាឡើយ។

## ករណីសិក្សា៖ សហរដ្ឋអាមេរិក

រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក កំណត់ប្រព័ន្ធដឹកនាំរដ្ឋសម្រាប់ប្រទេសនេះ និងជាច្បាប់កំពូលរបស់អាមេរិក។ ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញ ប្រធានាធិបតីគឺជាប្រមុខរដ្ឋ និងជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធ។ ប្រជាជនជនអាមេរិក មានសិទ្ធិបោះឆ្នោតជ្រើសរើសប្រធានាធិបតី (តាមរយៈក្រុមអ្នកបោះឆ្នោត ដែលហៅថា Electoral College (សូមមើលខាងក្រោម)។ ប្រធានាធិបតីដឹកនាំសមាជិកនៃស្ថាប័ននីតិប្រតិបត្តិសហរដ្ឋអាមេរិក ដែលមានដូចជាអនុប្រធានាធិបតី ក្រសួងជំនាញ ទីភ្នាក់ងារឯករាជ្យ និងក្រុមប្រឹក្សាភិបាល គណៈកម្មការ និងគណៈកម្មាធិការផ្សេងៗ។[15]

ប្រជាជនអាមេរិក មិនបោះឆ្នោតជ្រើសរើសប្រធានាធិបតីដោយផ្ទាល់ទេ។ ពួកគេបោះឆ្នោតជ្រើសរើសអ្នកតំណាងដើម្បីឲ្យអ្នកតំណាងទៅបោះឆ្នោតជំនួស។ ក្រុមអ្នកតំណាងនេះត្រូវបានហៅថា Electoral College មានចំនួន ៥៣៨ រូបជាចំនួនដែលធ្វើតាមប្រព័ន្ធសមាមាត្រក្នុងរដ្ឋនីមួយៗ។ ទោះបី

ដូច្នេះក្តី នៅក្នុងរដ្ឋនីមួយៗគណបក្សនយោបាយនីមួយៗបានជ្រើសរើសបេក្ខជនតំណាងទាំងនេះ។ ប្រសិនបើបេក្ខជននោះបានឈ្នះឆ្នោតនៅក្នុងរដ្ឋនីមួយៗ ពួកគេនឹងក្លាយជាសមាជិកនៃក្រុម Electoral College ហើយដូច្នេះនឹងត្រូវបោះឆ្នោតទៅឲ្យបេក្ខជនប្រធានាធិបតី ដែលគណបក្សរបស់ខ្លួនបង្ហាញឲ្យបោះឆ្នោត។ ការធ្វើបែបនេះមានន័យថា ប្រជាជនបោះឆ្នោតឱ្យអ្នកតំណាងដើម្បីឲ្យពួកគេទៅចូលរួមការបោះឆ្នោត Electoral College សម្រាប់ជ្រើសរើសប្រធានាធិបតី ជាជាងប្រជាពលរដ្ឋបោះឆ្នោតដោយផ្ទាល់។ រដ្ឋនៅសហរដ្ឋអាមេរិកភាគច្រើនប្រើវិធីសាស្ត្រហៅថា " អ្នកឈ្នះម៉ៅយកទាំងអស់ " (a winner-takes-all) ដែលមានន័យថា បេក្ខភាពដែលត្រូវបានតែងតាំងជាប្រធានាធិបតីមិនចាំបាច់ត្រូវទទួលបានសំឡេងឆ្នោតច្រើនជាងគេពីប្រជាជននោះទេ (ដូចការបោះឆ្នោតប្រធានាធិបតីសហរដ្ឋអាមេរិកថ្មីៗនេះ) ។ពិតណាស់ក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីអាមេរិក ឆ្នាំ ២០១៦ ហ៊ីលឡារី ឃ្លីនតុនទទួលបានសំឡេងឆ្នោតច្រើនជាង ដូណាល់ត្រាំ រហូតដល់ជិត ៣ លានសំឡេង ប៉ុន្តែប្រធានាធិបតីបច្ចុប្បន្នគឺ ដូណាល់ ត្រាំ។[16] ទោះយ៉ាងណាក៏ដោយ ក្រុមអ្នកបោះឆ្នោត Electoral College ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ។ យន្តការនេះត្រូវបានជ្រើសរើសដើម្បីសម្របសម្រួលរវាងយន្តការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ដោយសភា និងយន្តការបោះឆ្នោតដែលប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសប្រធានាធិបតីដោយផ្ទាល់។[17] ដោយសារតែយន្តការបោះឆ្នោតជ្រើសរើសប្រធានាធិបតីបែបនេះជាមធ្យោបាយសម្របសម្រួលមួយ យន្តការនេះហាក់ដូចជាមិនអាចផ្លាស់ប្តូរនៅពេលអនាគតឡើយ បើទោះបីជាយន្តការនេះបង្ហាញឲ្យឃើញពីលទ្ធផលដែលមិនមានលក្ខណៈប្រជាធិបតេយ្យក៏ដោយ។

ប្រធានាធិបតី អនុវត្តអំណាចរបស់ខ្លួនជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នតុលាការ ដែលអំណាចទាំងបីនេះមានភាពឯករាជ្យរៀងៗខ្លួន ប៉ុន្តែពឹងផ្អែកគ្នាទៅវិញទៅមកក្នុងដំណើរការមុខងាររបស់ខ្លួន។[15] កាតព្វកិច្ចចម្បងរបស់ប្រធានាធិបតី គឺការជំរុញអនុវត្តច្បាប់ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន ព្រឹទ្ធសភា(the Senate) និងរដ្ឋសភា(the House of Representatives)។ សភាទាំងពីរនេះរួមបញ្ចូលគ្នា មានឈ្មោះថា Congress។

សមាជិករដ្ឋសភា ៤៣៥ រូប គឺជាតំណាងរាស្ត្រមកពីរដ្ឋចំនួន ៥០ ដោយយោងទៅលើចំនួនប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋនីមួយៗ។ ជាឧទាហរណ៍ រដ្ឋដែលមានប្រជាជនច្រើន មានអ្នកតំណាងរាស្ត្រជាសមាជិករដ្ឋសភាច្រើនជាងរដ្ឋដែលមានប្រជាជនតិច។ អ្នកតំណាងរាស្ត្រម្នាក់ៗកាន់តំណែរយៈ-ពេល ២ ឆ្នាំមុនពេលការបោះឆ្នោតថ្មីម្តងទៀត។ រដ្ឋនីមួយៗមានសមាជិកព្រឹទ្ធសភា ២ រូប និងកាន់តំណែងរយៈពេល ៦ ឆ្នាំមុនការបោះឆ្នោតឡើងវិញ។

ទោះបីជាព្រឹទ្ធសភា និងរដ្ឋសភាមានអំណាចក្នុងការអនុម័តច្បាប់ជាមួយគ្នា សមាជិករដ្ឋសភាជាអ្នកតំណាងឲ្យក្រុមប្រជាជនមួយជាក់លាក់ ចំណែកឯសមាជិកព្រឹទ្ធសភាវិញ ជាតំណាងឲ្យផលប្រយោជន៍រដ្ឋណាមួយ។ ដូច្នេះសមាជិកព្រឹទ្ធសភាបំពេញតួនាទីរបស់ខ្លួន ដើម្បីផលប្រយោជន៍រដ្ឋ ជាជាងផលប្រយោជន៍ផ្សេងៗ។ ព្រឹទ្ធសភា គឺជាស្ថាប័នដែលគិតគូរលម្អិត និងមានភាពស៊ីជម្រៅចំពោះបញ្ហានានាជាងរដ្ឋសភា។ ទោះបីជាយ៉ាងនេះក្តី រដ្ឋធម្មនុញ្ញអាមេរិកផ្តល់អំណាចសំខាន់ៗទៅឲ្យរដ្ឋសភា

មានដូចជា អំណាចក្នុងការធ្វើច្បាប់ថវិការរដ្ឋ អំណាចក្នុងចោទប្រកាន់មន្ត្រីណាមួយ ក៏ដូចជាអំណាចក្នុងការជ្រើសរើសប្រធានាធិបតី ក្នុងករណីមានការជាប់គាំងណាមួយនៅក្នុងការបោះឆ្នោតរបស់ក្រុម Electoral College។

ស្ថាប័នតុលាការ របស់អាមេរិក មានតុលាការកំពូល (the Supreme Court) និងតុលាការសាលាឧទ្ធរណ៍ (the US Court of Appeals) ដែលមានសភាពីរសម្រាប់ជម្រះទាំងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។ មុខងារចម្បងរបស់តុលាការ គឺដោះស្រាយវិវាទរវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ បកស្រាយអត្ថន័យច្បាប់ និងធានាថាច្បាប់ទាំងឡាយគោរពទៅតាមរដ្ឋធម្មនុញ្ញ។ សមាជិកស្ថាប័នតុលាការត្រូវបានតែងតាំងដោយប្រធានាធិបតី និងត្រូវមានការឯកភាពពីព្រឹទ្ធសភា។

អាមេរិកមានភាពចម្លែកត្រង់ថា រដ្ឋនីមួយៗមានអំណាចក្នុងការធ្វើកំណែទម្រង់ច្បាប់ផ្សេងៗ ប៉ុន្តែត្រូវគោរពតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ។

### *៣.២.៣ ប្រព័ន្ធបែបប្រធានាធិបតីមិនពេញលេញ (Semi-presidential system)*

ប្រទេសដែលមានប្រព័ន្ធគ្រប់គ្រងរដ្ឋបែបប្រធានាធិបតីមិនពេញលេញ អំណាចនីតិប្រតិបត្តិត្រូវបែងចែកជាពីរទៅឲ្យប្រធានាធិបតីនៃសាធារណរដ្ឋ និងនាយករដ្ឋមន្ត្រី។

**ករណីសិក្សា៖ ប្រទេសបារាំង (របបសាធារណរដ្ឋបារាំងទី៥)**

នៅប្រទេសបារាំង ប្រធានាធិបតីគឺជាប្រមុខរដ្ឋ ដែលឈ្នះនៅក្នុងការបោះឆ្នោតជាតិ ហើយកាន់តំណែងរយៈពេល ៥ឆ្នាំ។ តួនាទីរបស់ប្រធានាធិបតីមានច្រើនដូចជា ធានាឲ្យមានការគោរពរដ្ឋធម្មនុញ្ញ ធ្វើជាប្រធានក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ប្រកាសឲ្យប្រើប្រាស់ច្បាប់ ធ្វើប្រជាមតិ រំលាយសភា បញ្ជាកងកម្លាំងប្រដាប់អាវុធ ការចរចា និងធ្វើសច្ចាប័នសន្ធិសញ្ញា។ រីឯនាយករដ្ឋមន្ត្រីវិញ គឺជាប្រមុខរដ្ឋាភិបាល និងត្រូវមានការទទួលខុសត្រូវចំពោះមុខរដ្ឋសភាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ នាយករដ្ឋមន្ត្រីត្រូវបានជ្រើសរើស ក្រោយពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ នាយករដ្ឋមន្ត្រី ដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់រដ្ឋាភិបាល ដើម្បីធានាការអនុវត្តច្បាប់ និងបទបញ្ជាឲ្យបានត្រឹមត្រូវ។ ទាំងប្រធានាធិបតី នាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី (ដែលបានតែងតាំងដោយប្រធានាធិបតីតាមរយៈការស្នើសុំរបស់នាយករដ្ឋមន្ត្រី) គឺជាកោសិកានៃស្ថាប័ននីតិប្រតិបត្តិនៃប្រទេសបារាំង។[18]

ស្ថាប័ននីតិប្បញ្ញត្តិរបស់ប្រទេសបារាំងមានសភាពីរ គឺរដ្ឋសភា និងព្រឹទ្ធសភា ដែលកាន់អំណាចនីតិប្បញ្ញត្តិ។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើសភាទាំងពីរមិនអាចសម្រេចទៅលើច្បាប់ណាមួយ រដ្ឋសភាមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ។

រដ្ឋសភាជាតិមានសមាជិក ៥៧៧ រូប និងកាន់តំណែងរយៈពេល ៥ឆ្នាំ។ សមាជិកសភា គឺជាមន្ត្រីរដ្ឋការ ហើយក៏ជាអ្នកតំណាងរាស្ត្រប្រចាំតំបន់ដែរ។[19]

បច្ចុប្បន្ន សមាជិកព្រឹទ្ធសភាមាន ៣៤៨ រូប។ សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតដោយមិនផ្ទាល់ដោយមន្ត្រីចំនួន ១៥០,០០០នាក់ដែលហៅថា "grands électeurs" (or the electoral college)

ដែលបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានោះ។ នៅក្នុងចំណោមមន្ត្រី "grands électeurs" រួមមាន សមាជិកក្រុមប្រឹក្សាតំបន់ (regional councilors) សមាជិកក្រុមប្រឹក្សាខេត្ត (department councilors) អភិបាលក្រុង សមាជិកក្រុមប្រឹក្សាក្រុងនៅក្នុងក្រុងធំៗ និងសមាជិករដ្ឋសភា។ រៀងរាល់ ៣ឆ្នាំមន្ត្រី ១៥០,០០០ រូបនេះ បោះឆ្នោតជ្រើសរើសពាក់កណ្តាលនៃសមាជិកព្រឹទ្ធសភា (អាណត្តិសមាជិកព្រឹទ្ធសភាមានរយៈពេល៦ឆ្នាំ)។ ទោះយ៉ាងក៏ដោយ ៩០ ភាគរយនៃមន្ត្រីជាអ្នកបោះឆ្នោតគឺត្រូវបានតែងតាំងដោយក្រុមប្រឹក្សាដែលបានរៀបរាប់ខាងលើ។

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ និងក្រុមប្រឹក្សារដ្ឋបារាំង គឺជាស្ថាប័នដ៏សំខាន់។ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញគឺជាយុត្តាធិការពិសេស ដែលមានតួនាទីពិនិត្យមើលទៅលើធម្មនុញ្ញភាពនៃច្បាប់ និងបទដ្ឋានអន្តរជាតិដែលប្រទេសបារាំងបានទទួលយក។ ក្រុមប្រឹក្សារដ្ឋ គឺជាអង្គជំនុំជម្រះឯករាជ្យ ដែលដើរតួនាទីជាស្ថាប័នដែលផ្តល់ប្រឹក្សាច្បាប់ទៅឲ្យរដ្ឋាភិបាល ហើយក៏មានតួនាទីជាតុលាការកំពូល ក្នុងការស្វែងរកយុត្តិធម៌ក្នុងទំនាស់រដ្ឋបាល។[20]

ប្រទេសបារាំងមានស្ថាប័នតុលាការ ដែលមានឯករាជ្យ និងមិនស្ថិតក្រោមអំណាចផ្ទាល់ពីស្ថាប័នដទៃពីរផ្សេងទៀត។

# ៤. ប្រព័ន្ធបោះឆ្នោត

## *៤.១ មុខងារនៃការបោះឆ្នោត*

របបប្រជាធិបតេយ្យដែលបង្ហាញពីឆន្ទៈប្រជាពលរដ្ឋ គឺជាប្រជាធិបតេយ្យដែលបញ្ចូលគំនិតមតិរបស់ប្រជាពលរដ្ឋទៅក្នុងប្រព័ន្ធដឹកនាំរដ្ឋ។ ការណ៍នេះអាចធ្វើទៅបានតាមរយៈការបោះឆ្នោត ដែលផ្តល់ឱកាសឲ្យប្រជាជនធ្វើការសម្រេចចិត្តតាមរយៈការបោះឆ្នោតដោយសេរី។ ដូច្នេះ មុខងារដ៏សំខាន់របស់ការបោះឆ្នោតគឺ ការធានាថាសមាសភាពគណបក្សនយោបាយនៅក្នុងសភា គឺជាតំណាងទស្សនៈរបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។ សភាត្រូវមានការទទួលខុសត្រូវចំពោះប្រជាជនម្ចាស់ឆ្នោត មានភាពរឹងមាំ និងស្ថិរភាព។ ទោះបីជាអញ្ចឹងក៏ពិតមែន មានប្រព័ន្ធបោះឆ្នោតផ្សេងៗជាច្រើន ដែលមានលក្ខណៈសម្បត្តិរៀងៗខ្លួន និងផ្សេងពីគ្នា។[21] ជាធម្មតាទេ ប្រទេសជាច្រើនប្រើប្រាស់ប្រព័ន្ធបោះឆ្នោតផ្សេងៗពីគ្នា ក្នុងការជ្រើសរើសសមាជិកសភានៅក្នុងប្រព័ន្ធទ្វិសភា ក៏ដូចជាការតែងតាំងប្រធានាធិបតី ឬនាយករដ្ឋ មន្ត្រី ដែលធ្វើឲ្យមានភាពស្មុគស្មាញច្រើននៅក្នុងទិដ្ឋភាពប្រព័ន្ធបោះឆ្នោតនានា។

## *៤.២ តើប្រព័ន្ធបោះឆ្នោតមានភាពខុសគ្នាដូចម្តេច?*

ទោះបីជាមានប្រព័ន្ធបោះឆ្នោតជាច្រើនក្តី ឯកសារនេះនឹងបកស្រាយតែប្រព័ន្ធដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅលើពិភពលោកប៉ុណ្ណោះដែលមានដូចជា៖ ប្រព័ន្ធឯកត្តនាម ប្រព័ន្ធសមាមាត្រអ្នកតំណាង (ដែលមានបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស) ប្រព័ន្ធបោះឆ្នោតពីរជុំ និងប្រព័ន្ធបោះឆ្នោតចម្រុះ។ អត្ថប្រយោជន៍ និងគុណវិបត្តិនៃប្រព័ន្ធបោះឆ្នោតទាំងនេះ នឹងត្រូវបកស្រាយជាបន្តបន្ទាប់។[22]

### *៤.២.១ ប្រព័ន្ធឯកត្តនាម*

ប្រព័ន្ធនេះអាចត្រូវហៅជាភាសាអង់គ្លេសថា Single Member Plurality ឬការបោះឆ្នោតសំឡេងភាគច្រើន (simple majority voting) ឬការបោះឆ្នោតបែបពហុ (plurality voting)។ ប្រព័ន្ធឯកត្តនាម ជាទូទៅមានន័យថា បុគ្គលណាមួយដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេពីប្រជាពលរដ្ឋ គឺត្រូវឈ្នះឆ្នោត និងត្រូវបានជ្រើសរើសធ្វើជាសមាជិកសភា ដូច្នេះមិនមានភាពចាំបាច់ក្នុងការទទួលបានសំឡេងឆ្នោតភាគច្រើន (លើសពី៥០ភាគរយ) ពីប្រជាពលរដ្ឋឡើយ ប៉ុន្តែត្រូវទទួលបានច្រើនជាងបេក្ខភាពដទៃទៀត(ជាលក្ខណៈបុគ្គល)។ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ មានដូចជានៅក្នុងការបោះឆ្នោតនៅរដ្ឋសភាចក្រភពអង់គ្លេស ( the UK's House of Commons) នៅក្នុងរដ្ឋភាគច្រើនរបស់អាមេរិកក្នុងការជ្រើសរើសសមាជិកសភា (Congress) និងនៅក្នុងសភារបស់ប្រទេសមួយចំនួនមានដូចជា មីយ៉ាន់ម៉ា ឥណ្ឌា កូរ៉េខាងត្បូង កាណាដា និងប្រទេសជាច្រើនទៀត។

### អត្ថប្រយោជន៍

ប្រព័ន្ធបោះឆ្នោតឯកត្តនាម មានភាពសាមញ្ញ ងាយធ្វើឲ្យអ្នកបោះឆ្នោតយល់ ក៏ដូចជា ងាយក្នុងការរាប់សន្លឹកឆ្នោត។ ប្រព័ន្ធនេះ ផ្តល់នូវទំនាក់ទំនងផ្ទាល់រវាងបេក្ខភាពសមាជិកសភា និងប្រជាជនក្នុងភូមិភាគ និងមណ្ឌលដែលសមាជិកសភាទទួលបន្ទុក។ គណបក្សធំៗ ដែលមានឱកាសឈ្នះអាសនៈភាគច្រើនក្នុងសភា ជាទូទៅអាចបង្កើតរដ្ឋាភិបាលដែលមានស្ថិរភាព និងរឹងមាំ ដោយមិនចាំបាច់ត្រូវមានសម្ព័ន្ធជាមួយបក្សដទៃទៀត ក៏ដូចជាមិនចាំបាច់ធ្វើការសម្របសម្រួលគោលនយោបាយជាមួយគណបក្សដទៃដែលមានគោលជំហរផ្សេង។

### គុណវិបត្តិ

ប្រព័ន្ធបោះឆ្នោតឯកត្តនាម មានបញ្ហាច្រើនទាក់ទងនឹងការខ្ជះខ្ជាយសន្លឹកឆ្នោត ។ គណបក្សធំៗជាធម្មតាតែងតែមានប្រៀបជាងគណបក្សតូចៗ បើទោះបីថាគណបក្សតូចៗទទួលបានសំឡេងឆ្នោត និងអាសនៈសភាមួយចំនួន។ កត្តានេះ ធ្វើឲ្យប្រជាជនមានអារម្មណ៍ថា ការបោះឆ្នោតឲ្យគណបក្សតូចៗ គឺជាការខ្ជះខ្ជាយសន្លឹកឆ្នោត។ ជាងនេះទៅទៀត សមាសភាពសមាជិកសភាមិនបានតំណាងឲ្យទស្សនៈពិតរបស់ប្រជាជន ហើយ គណបក្សដែលទទួលសំឡេងឆ្នោតភាគច្រើនពីប្រជាពលរដ្ឋ អាចមិនមានលទ្ធភាពក្នុងការបង្កើតរដ្ឋាភិបាល ទោះបីជាមានការគាំទ្រតាមរយៈសន្លឹកឆ្នោតដ៏ច្រើនជាងគណបក្សដទៃ។ ជាឧទាហរណ៍ គណបក្សមួយដែលទទួលបានសន្លឹកឆ្នោតគាំទ្រទូទាំងប្រទេស។

ជាងនេះទៅទៀត ប្រសិនបើចំនួនអាសនៈរបស់គណបក្សមួយមិនគ្រប់គ្រាន់ក្នុងសភាក្នុងការប្រកួតប្រជែង គណបក្សនោះមិនអាចឆ្លើយតបនឹងតម្រូវការរបស់សាធារណជនឡើយ។ ប្រព័ន្ធបោះឆ្នោតនេះពឹងផ្អែកទៅលើតំបន់បោះឆ្នោតដែលមិនបានគិតពីបម្រែបម្រួលប្រជាសាស្ត្រឡើយ។

### ៤.២.២ ប្រព័ន្ធសមាមាត្រ (រួមមានបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស)

ប្រព័ន្ធសមាមាត្រលុបបំបាត់ការខ្ជះខ្ជាយសន្លឹកឆ្នោត ដោយសារគណបក្សជាច្រើន គឺតំណាងឲ្យប្រជាជននៅក្នុងសភា ដោយយោងទៅលើភាគរយសន្លឹកឆ្នោតដែលពួកគេទទួលបាន។ នៅក្នុងប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស គណបក្សធ្វើបញ្ជីបេក្ខភាពតំណាងរាស្ត្រ និងចំនួនអាសនៈត្រូវបានបែលកទៅឲ្យគណបក្សនីមួយៗ ដោយផ្អែកទៅលើភាគរយនៃសំឡេងឆ្នោតដែលគេទទួលបាន និងបេក្ខភាពត្រូវរើសចេញពីបញ្ជីតាមលំដាប់លេខរៀង។ កម្ពុជាប្រើប្រាស់ប្រព័ន្ធនេះ ដូចនឹងប្រទេសផ្សេងៗទៀតមានដូចជា អូទ្រីស ដាណឺម៉ាក ម៉ូហ្សំមប៊ីក ប៉ូឡូញ និងប្រទេសដទៃទៀតជា ច្រើន។

### អត្ថប្រយោជន៍

នៅក្នុងប្រព័ន្ធនេះ គណបក្សតូចៗក៏មានឱកាសឈ្នះឆ្នោត ហើយអាចមានអាសនៈនៅក្នុងសភា។ ប្រព័ន្ធសមាមាត្រទាំងនេះបន្ធូរបន្ថយនិន្នាការនៃការបោះឆ្នោតដោយប្រើប្រាស់យុទ្ធសាស្ត្រ៖ ដោយសារតែប្រជាជនមិនអាចបោះឆ្នោតទៅឲ្យបេក្ខជនដែលគេចូលចិត្តជាងគេ ប្រជាជននឹងប្រើប្រាស់យុទ្ធសាស្ត្រ ដោយបោះឆ្នោតឲ្យបេក្ខជនផ្សេង ដែលអាចធ្វើឲ្យបេក្ខជនដែលប្រជាជនមិនចូលចិត្តជាងគេមិនអាចឈ្នះឆ្នោត។ ដោយសារគ្មានគណបក្សតែឯកឯងណាមួយដែលមានអាសនៈភាគច្រើនដាច់គេ ប្រព័ន្ធនេះជំរុញឲ្យមានការធ្វើសម្បទាន និងការស្រុះស្រួលគ្នា ក្នុងការសម្រេចចិត្តលើទស្សនៈមតិផ្សេងៗ។

ជាងនេះទៅទៀត បញ្ជីសមាមាត្រអ្នកតំណាងសមាជិកគណបក្ស ផ្តល់លទ្ធភាពច្រើនក្នុងការជ្រើសរើសបេក្ខភាព ដែលអាចមកពីក្រុមជនជាតិភាគតិច ឬ ជាស្ត្រី ដែលអាចដាក់ចូលក្នុងបញ្ជីនេះ។

### គុណវិបត្តិ

ទោះជាយ៉ាងណាក៏ដោយ ភាពខ្វះខាតនៃសំឡេងភាគច្រើនអាចរារាំងសភាក្នុងការធ្វើកំណែទម្រង់ ផ្សេងៗមានដូចជា ការជជែកពិភាក្សាដែលមិនសូវមានប្រសិទ្ធភាព និងការសម្របសម្រួលច្រើនធ្វើឲ្យកំណែទម្រង់ពុំសូវមានប្រសិទ្ធភាព។ ប្រសិនបើមានការសហការគ្នារវាងគណបក្សនយោបាយ ដើម្បីធ្វើកំណែទម្រង់មួយ សភាហាក់បង្ហាញពីភាពទន់ខ្សោយ និងធ្វើការសម្រេចចិត្តមិនបានល្អ ដោយសារការមិនបានដោះស្រាយបញ្ហាជាច្រើន។ ជាងនេះទៀត ប្រព័ន្ធនេះ អាចធ្វើឲ្យគណបក្សតូចៗដែលមានគំនិតជ្រុលនិយម មានអំណាចកាន់តែខ្លាំង។

គុណវិបត្តិផ្សេងទៀត នៅក្នុងប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស គឺមានទំនាក់ទំនងខ្សោយជាមួយអ្នកបោះឆ្នោតក្នុងមណ្ឌល ។ ស្ថានភាពនេះ មានហានិភ័យដែលអាចធ្វើឲ្យបញ្ហាមូលដ្ឋានមិន ត្រូវបានដោះស្រាយ។ បញ្ជីសមាមាត្រអ្នកតំណាងគណបក្ស ផ្តល់អំណាចឲ្យអ្នកដឹកនាំគណបក្សមានអំណាចក្នុងការជ្រើសរើសបេក្ខភាពណាមួយដែលអាចនឹងបោះឆ្នោត។ ជាងនេះទៀត បេក្ខភាពឯករាជ្យ ដែលមិនស្ថិតក្នុងគណបក្សណាមួយ ប្រហែលជាមិនត្រូវបានរាប់បញ្ចូលឡើយ។

### ៤.២.៣ ប្រព័ន្ធបោះឆ្នោតពីរជុំ

នៅក្នុងប្រព័ន្ធបោះឆ្នោតពីរជុំ អ្នកបោះឆ្នោត បោះឆ្នោតឲ្យបេក្ខជនដែលពួកគេចូលចិត្ត។ ប្រព័ន្ធអាចហៅជាភាសាអង់គ្លេសថា the second ballot ឬ run-off voting។ ប្រសិនបើមិនមានបេក្ខភាពដែលអាចទទួលបានសំឡេងតាមការកំណត់ (ជាទូទៅយ៉ាងហោចណាស់ ៥០ភាគរយ) បេក្ខភាពដែលមានសំឡេងឆ្នោតតិចជាងគេ គឺត្រូវដម្រុះចោល។ ជុំទីពីរនៃការបោះឆ្នោតជាការកាត់សេចក្តីដើម្បីរកអ្នកឈ្នះ។ ក្នុងចំណោមប្រទេសជាច្រើន ប្រទេសបារាំងប្រើប្រាស់ប្រព័ន្ធនេះ ក្នុងការជ្រើសរើស ប្រធានាធិបតី និងសមាជិកសភា។ ប្រទេសមួយចំនួនទៀត ដូចជាប្រេស៊ីល អេស៊ីប ឥណ្ឌូនេស៊ី និងប៉េរូ ក៏ប្រើប្រាស់ប្រព័ន្ធនេះដែរ ដើម្បីជ្រើសរើសប្រធានាធិបតី។

#### អត្ថប្រយោជន៍

ប្រព័ន្ធនេះ ជួយឲ្យអ្នកបោះឆ្នោតមានឱកាសប្តូរចិត្តក្នុងការបោះឆ្នោតលើកទីពីរ ដែលនឹងរកបានអ្នកឈ្នះដាច់។ ប្រព័ន្ធនេះ ក៏ជួយឲ្យបេក្ខជនដែលចាញ់ក្នុងជុំទី១ មានឥទ្ធិពលចំពោះបេក្ខជនដទៃក្នុងជុំទីពីរ (អ្នកដែលធ្លាប់គាំទ្របេក្ខភាពពីមុន អាចផ្លាស់ប្តូរចិត្តមកគាំទ្របេក្ខភាពថ្មី)។ ប្រព័ន្ធនេះ ក៏លុបបំបាត់បញ្ហាដែលមានក្នុងប្រព័ន្ធបោះឆ្នោតឯកត្តនាម នៅពេលដែល គណបក្សពីរដែលទទួលបានសំឡេងឆ្នោតស្រដៀងគ្នាបំបែកសន្លឹកឆ្នោត ដែលអាចធ្វើឲ្យបេក្ខជនដែលមានប្រជាប្រិយភាពតិចឈ្នះ។

#### គុណវិបត្តិ

តម្រូវការការបោះឆ្នោតពីរដងជាបន្តបន្ទាប់ ធ្វើឲ្យមានសំពាធដល់ផ្នែករដ្ឋបាល និងអាចធ្វើឲ្យលទ្ធផលមិនមានសមាមាត្រដូចនឹងប្រព័ន្ធឯកត្តនាម ជាពិសេសនៅពេលបេក្ខជនចុងក្រោយនៅជុំទី២ ត្រូវចាញ់ដោយខុសសំឡេងតិចតួចជាមួយអ្នកឈ្នះ ។

### ៤.២.៤ ប្រព័ន្ធបោះឆ្នោតចម្រុះ

ដើម្បីចៀសវាងកំហុសមួយចំនួន ដែលមានក្នុងប្រព័ន្ធខាងលើ ប្រទេសមួយចំនួនប្រើប្រាស់ប្រព័ន្ធបោះឆ្នោតចម្រុះ បើទោះបីជាមានភាពខុសគ្នាច្រើនពីប្រព័ន្ធដទៃ។ ប្រព័ន្ធនេះមានពីរប្រភេទគឺ Parallel Voting និងប្រព័ន្ធសមាមាត្រសមាជិកចម្រុះ។

Parallel Voting ពិពណ៌នាពីប្រព័ន្ធបោះឆ្នោតចម្រុះ ដែលអ្នកបោះឆ្នោតចូលរួមការបោះឆ្នោតពីរផ្សេងគ្នា សម្រាប់ជ្រើសរើសសមាជិកសភាតែមួយដែលប្រើប្រាស់ប្រព័ន្ធផ្សេងៗគ្នា។ Parallel Voting ខុសប្លែកពីប្រព័ន្ធសមាមាត្រសមាជិកចម្រុះ ដែលការបោះឆ្នោតមានតែមួយដងប៉ុណ្ណោះ ហើយការបោះឆ្នោតរបស់បក្សជាការកំណត់បែងចែកអាសនៈសម្រាប់គណបក្សនីមួយៗនៅក្នុងនីតិកាល ដើម្បីជាការសងមកវិញចំពោះលទ្ធផលដែលមិនមានសមាមាត្រនៅក្នុងការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន។

ជាឧទាហរណ៍ ប្រទេសជប៉ុនប្រើប្រាស់ប្រព័ន្ធ Parallel Voting ដែលរួមបញ្ចូលទាំងប្រព័ន្ធឯកត្តនាម និងប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស ក្នុងការជ្រើសរើសសមាជិកសភា (House of

Representatives)។ អាសនៈចំនួន ២៩៥ត្រូវធ្វើឡើងតាមប្រព័ន្ធឯកត្តនាម និង១៨០អាសនៈទៀត ត្រូវធ្វើឡើងតាមប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស។ ចំណែកឯការបោះឆ្នោតនៅរុស្ស៊ីវិញ អាសនៈសភា (State Duma) ចំនួន៤៥០ ត្រូវបានបែងចែកតាមប្រព័ន្ធពីរ៖ អាសនៈចំនួន២២៥ត្រូវបានជ្រើសរើសតាមប្រព័ន្ធឯកត្តនាម និង អាសនៈចំនួន២២៥ទៀតត្រូវបានជ្រើសរើសតាមប្រព័ន្ធបញ្ជីសមាមាត្រអ្នកតំណាងគណបក្ស។ ប្រព័ន្ធសមាមាត្រសមាជិកចម្រុះត្រូវបានប្រើប្រាស់នៅប្រទេស នូវែលសេឡង់ និង អាល្លឺម៉ង់។

## គុណសម្បត្តិ និងគុណវិបត្តិ

ទោះបីប្រព័ន្ធ Parallel voting និងប្រព័ន្ធសមាមាត្រសមាជិកចម្រុះ ត្រូវបានយកមកអនុវត្តដើម្បីធ្វើឲ្យមុខងារតំណាងក្នុងលទ្ធិប្រជាធិបតេយ្យនៅក្នុងសភាកាន់តែមានភាពច្បាស់លាស់ ប្រព័ន្ធទាំងនេះហាក់បង្កើតឲ្យមានសមាជិកសភាពីរថ្នាក់ និងបង្ហាញឲ្យឃើញពីភាពមិនព្រមព្រៀងគ្នា និងថែមទាំងមានភាពស្មុគស្មាញ និងភាពភាន់ច្រលំសម្រាប់ប្រជាជន។

## *៤.៣. សេចក្តីសង្ខេប*

តាមរយៈការពិពណ៌នាខាងលើ ពិតណាស់ប្រព័ន្ធផ្សេងៗសម្រាប់ការបោះឆ្នោតសភា ឬការបែងចែកអំណាចគ្រប់គ្រងរដ្ឋមិនអាចមានភាពល្អឥតខ្ចោះឡើយ។ ប្រទេសនីមួយៗមានការរៀបចំផ្ទាល់ខ្លួនដោយយោងទៅលើប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ពួកគេ។ ហើយប្រទេសខ្លះទៀតបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធបោះឆ្នោតថ្មីជំនួសឲ្យប្រព័ន្ធដែលធ្លាប់បានរៀបចំដោយប្រទេសដទៃ។ ការអនុវត្តប្រជាធិបតេយ្យមិនអាចល្អឥតខ្ចោះគ្រប់ពេលឡើយ ហើយការរៀបចំផ្សេងៗតែងតែមានគុណសម្បត្តិ និងគុណវិបត្តិខានមិនបាន។

## *៤.៣.១ ស្ថិតិសកលទាក់ទងនឹងថវិកាសភា និងបុគ្គលិក*

របាយការណ៍សភាសកល (global statistics)[2] បានបង្ហាញថា ថវិកាសម្រាប់សភាទាបបំផុតនៅប្រទេសឥណ្ឌាដែលចំនួនត្រឹមតែ ០.២៥ ដុល្លារអាមេរិក សម្រាប់១នាក់ (per capita) និងខ្ពស់បំផុតនៅប្រទេសអ៊ីសឡង់ ដែលមានរហូតដល់ ៥៩.៤៧ ដុល្លារអាមេរិក សម្រាប់ ១នាក់(per capita)។ រីឯទួរលេខចំនួនបុគ្គលិកសភាវិញ នៅអាមេរិកមានចំនួន ១៥. ៩០៧នាក់ នៅកម្ពុជាមានចំនួន ១.៦៩២ នាក់ តិចជាងអាមេរិក ប៉ុន្តែច្រើនជាង កូរ៉េខាងត្បូងដែលមានចំនួន ១.៤៥៤នាក់ និងអេស្ប៉ាញដែលមានចំនួន ៨៤៤នាក់។ តាមរយៈទួរលេខនេះ អាចបញ្ជាក់បានថា សមាជិកសភាអាមេរិកម្នាក់អាចមានបុគ្គលិកចំនួន ២៩.៧នាក់ ហើយកម្ពុជាវិញអាចមានបុគ្គលិក ៩.២ នាក់ ចំណែកឯបារាំងវិញមាន ២.៦ នាក់ ហុងគ្រី ១.៦ នាក់ និងម៉ាឡាវីអាចមានបុគ្គលិកចំនួន ០.៨នាក់។

## ៤.៣.២ សារៈសំខាន់ក្នុងការបញ្ចូលស្ត្រីឲ្យក្លាយជាសមាជិកសភា

របាយការណ៍សភាសកល (global statistics) បង្ហាញថា ពុំទាន់មានស្ត្រីគ្រប់គ្រាន់ក្នុងមុខងារតំណាងឲ្យប្រជាពលរដ្ឋនៅក្នុងសភានានានៅឡើយ។ ស្ត្រីជាសមាជិកសភាមានចំនួនតែ ១៩.២៥ភាគរយប៉ុណ្ណោះនៅទូទាំងពិភពលោក និងក្នុងចំណោមសភា ២០.៤៣ ភាគរយ ទូទាំងពិភពលោក មានស្ត្រីតិចជាង ១០ ភាគរយជាសមាជិកសភា[2] យោងតាមអង្គការមិនមែនរដ្ឋាភិបាល (Sithi.org) បង្ហាញថា ការបោះឆ្នោតជាតិឆ្នាំ ២០១៣ នៅកម្ពុជា មានអាសនៈចំនួន ២៥ ក្នុងចំណោម១២៣ ត្រូវបានឈ្នះដោយស្ត្រី ដែលស្មើនឹង (២០.៣៣ភាគរយ)។[23] ការស្ទាបស្ទង់របស់សហភាពអន្តរសភា (IPU) ក្នុងឆ្នាំ ២០០០[24] គូសបញ្ជាក់អំពីមូលហេតុសំខាន់ៗ ដែលតម្រូវឲ្យមានវិសមភាពយេនឌ័រជាងមុននៅក្នុងសភា។ ការ ស្ទាបស្ទង់ដែលធ្វើឡើងតាមរយៈការធ្វើសម្ភាសន៍ជាមួយស្ត្រីជាច្រើនបានបង្ហាញដូចតទៅ៖

- ភាពស្មើគ្នា និងយុត្តិធម៌៖ដើម្បីឲ្យមានសមធម៌ចំពោះស្ត្រីដែលមានចំនួនប្រមាណពាក់កណ្តាលនៃប្រជាជន លុះត្រាតែមានអ្នកតំណាងស្ត្រីឲ្យបានសមស្របនៅក្នុងសភារបស់ពួកគេ។
- ស្ត្រីផ្លាស់ប្តូរដំណើរការនយោបាយ និងវប្បធម៌៖ ស្ត្រីមិនសូវចូលចិត្តប្រកែកតវ៉ាប៉ុន្តែចូលចិត្តជំរុញឲ្យមានការមូលមតិគ្នា ស្វែងរកដំណោះស្រាយចំពោះបញ្ហាផ្សេងៗ ជាជាងការចង់បានពិន្ទុក្នុងឆាកនយោបាយ។
- ស្ត្រីផ្លាស់ប្តូរភាពលំអៀងរបស់បុរសនៅក្នុងអាទិភាពនយោបាយ៖ ស្ត្រីហាក់ដូចជាយកចិត្តទុកដាក់ច្រើនជាងបុរសទៅលើបញ្ហាសង្គម ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីដែលកំពុងមានធុរៈចិញ្ចឹមកុមារ។ ស្ត្រីមានការប្រុងប្រយ័ត្នចំពោះសេដ្ឋកិច្ច ការអប់រំ និងបញ្ហាសុខភាព។

ទោះបីថាវិសមភាពយេនឌ័រក្នុងចំណោមសមាជិកសភាកំពុងមានការរីកចម្រើននៅទូទាំងពិភពលោក វិសមភាពនេះនៅតែត្រូវឈានឲ្យដល់កម្រិត ៥០ ទល់នឹង៥០។[8]

## ៤.៣.៣ ទំនាក់ទំនងរវាង ប្រជាជន និងសភា

របាយការណ៍សភាសកល (Global Parliamentary Report ) ឆ្នាំ ២០១២ ក៏បានបង្ហាញពីលទ្ធផលស្ទាបស្ទង់ពីទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងសភា។[2] ដោយបានសួរទៅកាន់សមាជិកសភា ៦៦៣ រូប នៅទូទាំងពិភពលោក តាមរយៈការស្ទាបស្ទង់ដោយប្រើគំរូចៃដន្យ ៨៥ ភាគរយនៃអ្នកឆ្លើយសំណួរ បាននិយាយថា ការធ្វើច្បាប់គឺជាការងារចម្បង និងការតាមដានរដ្ឋាភិបាល គឺជាការងារបន្ទាប់។ អ្នកផ្តល់ចម្លើយជាសមាជិកសភាមាន (៦០ ភាគរយ) បានចាត់ទុកថា ការដោះស្រាយបញ្ហាប្រជាពលរដ្ឋមូលដ្ឋាន គឺជាការងារដ៏សំខាន់។ ចំណែកឯសាធារណជនរហូតដល់ (៧១,៤ ភាគរយ) មានការយល់ស្របចំពោះគំនិតនេះ។ ភាពស្រដៀងគ្នាមួយទៀត គឺសមាជិកសភាចំនួន ៤១,៤ ភាគរយ បានចាត់ទុកថា ការគាំទ្រដល់គណបក្សនយោបាយគឺជាការដ៏សំខាន់ ចំណែកឯសាធារណជនមាន ២៧ ភាគរយ

ដែលយល់ស្របនឹងគំនិតនេះ។ នៅពេលសួរអំពីបញ្ហានានាដែលរារាំងចំពោះប្រសិទ្ធភាពសភា សមាជិកសភា ៦៥,១ ភាគរយ បាននិយាយពីកង្វះធនធានសម្រាប់ការងារតាមមណ្ឌលភូមិភាគ ។ ៦៥ ភាគរយនៃសមាជិកសភាដែលត្រូវបានសម្ភាសន៍បាននិយាយថា នេះជាបញ្ហាមួយសំខាន់សម្រាប់ប្រសិទ្ធភាពការងាររបស់ពួកគាត់។

តាមរយៈភាពខុសប្លែកគ្នាចំពោះទិដ្ឋភាពនៃប្រទេសនីមួយៗ ផ្នែកបន្ទាប់នឹងពិពណ៌នាអំពីរបៀបដែលសភា និងរដ្ឋាភិបាលកម្ពុជាដំណើរការ។

## *៤.៤ ប្រព័ន្ធបោះឆ្នោតនៅកម្ពុជា*

ប្រព័ន្ធបោះឆ្នោតជ្រើសរើសសមាជិកសភាកម្ពុជា ជាចម្បងត្រូវបានរៀបចំដោយអង្គការសហប្រជាជាតិ (ច្បាប់បោះឆ្នោតអ៊ុនតាក់ឆ្នាំ ១៩៩៣) ដែលបង្កើតឲ្យមានការបោះឆ្នោតតាមប្រព័ន្ធតំណាងសមាមាត្រនៅដើមទសវត្សរ៍ឆ្នាំ ១៩៩០។ ប្រព័ន្ធទ្វិសភាកម្ពុជាមានដើមកំណើតចាប់តាំងពីពេលដែលមានការតាក់តែងរដ្ឋធម្មនុញ្ញដំបូងនៅឆ្នាំ១៩៤៧ មកម្លេះ។ ប៉ុន្តែប្រព័ន្ធនេះបានបាត់ទៅវិញក្នុង ១៩៧៥។ ព្រឹទ្ធសភាកម្ពុជា ត្រូវបានបង្កើតឡើងវិញក្នុងឆ្នាំ ១៩៩៩ ដែលក្នុងនីតិកាលទី១(១៩៩៩-២០០៦)នេះ សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវបានជ្រើសរើសចេញពីក្នុងចំណោមឥស្សរជនជាសមាជិកសមាជិកានៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២ ហើយត្រូវបានត្រូវបានតែងតាំងដោយព្រះមហាក្សត្រ។ ចាប់ពីនីតិកាលទី២មក ក្រៅពីសមាជិកព្រឹទ្ធសភា ០២ រូបចាត់តាំងដោយព្រះមហាក្សត្រ និង ០២ រូបជ្រើសតាំងដោយរដ្ឋសភា សមាជិកព្រឹទ្ធសភាដទៃទៀត ត្រូវបានជ្រើសតាំងដោយការ បោះឆ្នោតជាអសកល ដោយមានអង្គបោះឆ្នោតគឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ។ ក្រុមប្រឹក្សាឃុំត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋ តាមរយៈការបោះឆ្នោតតាមប្រព័ន្ធតំណាងសមាមាត្រ រៀងរាល់៥ឆ្នាំម្តង និងបានដំណើរការ ៣លើករួចមកហើយនៅក្នុងឆ្នាំ (២០០២ ២០០៧ និង ២០១២)។

ទាក់ទងនឹងការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ខេត្តនីមួយៗ ឬរាជធានី គឺជាមណ្ឌលបោះឆ្នោត ហើយចំនួនអាសនៈដែលត្រូវបានបែងចែកទៅតាមមណ្ឌលនីមួយៗគឺសមាមាត្រទៅនឹងចំនួនប្រជាជន (ច្បាប់បោះឆ្នោតអ៊ុនតាក់ UNTAC ឆ្នាំ១៩៩៣)។ អាសនៈនៅក្នុងខេត្តនីមួយៗត្រូវចាត់តាំងទៅឲ្យបេក្ខភាពតំណាងរាស្ត្រដោយយោងលើបញ្ជីទម្រង់បិទ ដែលត្រូវបានដាក់ជូនដោយគណបក្សនីមួយៗទៅឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បេក្ខភាពតំណាងរាស្ត្រ ត្រូវតែងតាំងក្រោមការសម្រេចចិត្តរបស់គណបក្សនយោបាយ។

យោងតាមច្បាប់បោះឆ្នោតអង្គការសហប្រជាជាតិ ការបែលកអាសនៈដំបូងផ្តល់ឲ្យគណបក្សនីមួយៗនូវចំនួនអាសនៈដោយផ្អែកទៅលើសមាមាត្រនៃសន្លឹកឆ្នោត។ ប្រសិនបើមានចំនួនអាសនៈដែលត្រូវបំពេញបន្ថែម គណបក្សដែលមានសំឡេងឆ្នោតច្រើនជាងគេមានសិទ្ធិទទួលបានអាសនៈបន្ថែមនេះនៅក្នុងមណ្ឌលណាមួយ។

រូបមន្តនៃការបោះឆ្នោតសម្រាប់ព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំចំនួនជាង ១,៦០០ ពិតជាមានភាពស្រដៀងគ្នាទៅការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា។ សមាជិករដ្ឋសភាត្រូវបានបោះឆ្នោតជ្រើស-តាំងតាមប្រព័ន្ធសមាមាត្រ ដែលមានតែគណបក្សនយោបាយដែលបានចុះបញ្ជីនៅថ្នាក់ជាតិប៉ុណ្ណោះដែលអាចធ្វើការប្រកួតប្រជែងបាន។ដូច្នេះ ច្បាប់បោះឆ្នោតរបស់កម្ពុជាបច្ចុប្បន្ន កើតចេញពីលក្ខណៈពិសេសនៃការបណ្ដុះបណ្ដាលដំបូងនៃដំណើរការផ្លាស់ប្ដូរ។

ការកំណត់យកខេត្ត ធ្វើជាមណ្ឌលបោះឆ្នោត គឺជាលក្ខណៈដ៏ចម្បងបំផុតនៃប្រព័ន្ធបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា។ រាជធានីខេត្តទាំង ២៥ របស់កម្ពុជា មានភាពខុសគ្នាខ្លាំងចំពោះចំនួនប្រជាជន។ នេះគឺដោយសារមណ្ឌលបោះឆ្នោតកំណត់ចំពោះព្រំប្រទល់រាជធានីខេត្ត និងកំណើនប្រជា-ជនក្នុង ឆ្នាំ ១៩៩១ និង១៩៩៣ម្លេះ ហើយការនៅតែអនុវត្តបែបនេះមិនបានគិតទៅដល់ទំនើបកម្មសង្គម និងសេដ្ឋកិច្ច ក៏ដូចជាពុំបានគិតទៅដល់បម្រែបម្រួលប្រជាសាស្ត្រតាំងពី២៥ឆ្នាំមុនមកដល់បច្ចុប្បន្ននេះ។ សព្វថ្ងៃមណ្ឌលបោះឆ្នោតបង្ហាញឲ្យឃើញនូវភាពខុសគ្នាយ៉ាងខ្លាំងចំពោះទំហំចំនួននៃអ្នកបោះឆ្នោត៖ ឧទាហរណ៍ ចំនួនអ្នកបោះឆ្នោតដែលបានចុះបញ្ជីនៅក្នុងខែមិថុនា ឆ្នាំ ២០១៣ មានចាប់ពី ២៥, ៦៦៥ នាក់នៅក្នុងខេត្តកែប រហូតដល់ ១,២០០,០០០ នាក់ខេត្តកំពង់ចាម ដែលជាមណ្ឌលខេត្តធំជាងគេ។ ព្រំប្រទល់មណ្ឌលរាជធានីខេត្ត និងចំនួនអាសនៈសម្រាប់ភូមិភាគនីមួយៗពុំមានការប្រែប្រួល ចាប់តាំងពីឆ្នាំ ២០០៨ រហូតដល់ឆ្នាំ ២០១៣ ហើយក៏មានគម្លាតបោះឆ្នោតរវាងមណ្ឌលបោះឆ្នោតតូចៗ (ទាក់ទងនឹងចំនួនអ្នកបោះឆ្នោត និងចំនួនអាសនៈ) ដែលមានការកើនឡើងជាប្រវត្តិសាស្ត្រក្នុងឆ្នាំ ២០១៣។

ក្នុងខែមីនា ២០១៥ សភាកម្ពុជាបានអនុម័ត ជាឯកច្ឆ័ន្ទទៅលើច្បាប់បោះឆ្នោតចំនួនពីរ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ច្បាប់ទាំងនេះកើតចេញពីការសម្របសម្រួលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។[25]

ច្បាប់បោះឆ្នោតថ្មីនឹងជួយបង្កើនចំនួនអាសនៈពី ១២៣ ទៅដល់ ១២៥ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០១៨ ប៉ុន្តែការកើនឡើងបន្តិចនៃចំនួនអាសនៈនេះ នឹងជួយឲ្យសមាមាត្រនៃអាសនៈនៅតាមណ្ឌលបោះឆ្នោតមានភាពសមស្របជាងមុនតែបន្តិចទេ ។[26]

ជាងនេះទៀត ខេត្តធ្ងាយៗ មានអ្នកតំណាងច្រើនពេក ផ្ទុយពីរាជធានីខេត្ត ដែលមានប្រជាជនច្រើនតែមានអ្នកតំណាងតិច។ ជាចុងក្រោយ ភាគច្រើន នៃមណ្ឌលបោះឆ្នោតគឺតូចៗ៖ មណ្ឌលបោះឆ្នោត លក្ខណៈមធ្យម ជ្រើសតាំងតំណាងរាស្ត្រ ៤រូបតែប៉ុណ្ណោះ ហើយចំណែកឯមណ្ឌលបោះឆ្នោតចំនួន១៣ ក្នុងចំណោម២៥ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតែ៥រូបឬតិចជាងនេះ។

## ៥. សភាកម្ពុជា

### *៥.១ តើទម្រង់ និងលក្ខខណ្ឌនៃសភាកម្ពុជាមានលក្ខណៈដូចម្ដេច?*

### *៥.១.១. ប្រវត្តិនៃការបង្កើតសភាកន្លងទៅថ្មីៗនេះ*

បន្ទាប់ពីសង្គ្រាមស៊ីវិលដ៏លំបាកវេទនា ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ បានធ្វើឲ្យកម្ពុជាមានសន្តិភាពជាងមុន មានការអភិវឌ្ឍ ឈប់មានការបាញ់បោះ និងបង្កើតឲ្យមានការបោះឆ្នោតប្រជាធិបតេយ្យឆ្នាំ ១៩៩៣។[27] ការបោះឆ្នោតនេះ បានបង្កើតរាជរដ្ឋាភិបាលដែលដឹកនាំដោយ សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី ១ និងសម្ដេច ហ៊ុនសែន ជានាយករដ្ឋមន្ត្រីទី២។ រដ្ឋធម្មនុញ្ញថ្មី ត្រូវបានប្រកាសឲ្យប្រើនៅក្នុង ខែកញ្ញា១៩៩៣ ដែលកំណត់ឲ្យព្រះរាជាណាចក្រកម្ពុជា ប្រកាន់របបរាជានិយម ដែលមានប្រព័ន្ធនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។[28] ការណ៍នេះមានន័យថាព្រះមហាក្សត្រគឺជាព្រះប្រមុខរដ្ឋ ចំណែកឯនាយករដ្ឋមន្ត្រីគឺជាប្រមុខដឹកនាំរាជរដ្ឋាភិបាល (ស្រដៀងនឹងប្រព័ន្ធរបស់ចក្រភពអង់គ្លេស)។

### *៥.១.២ រដ្ឋធម្មនុញ្ញ និងប្រព័ន្ធគ្រប់គ្រងរដ្ឋ*

រដ្ឋធម្មនុញ្ញ[29] កំណត់នូវមូលដ្ឋានសម្រាប់ការគ្រប់គ្រងប្រទេសកម្ពុជា។ រដ្ឋធម្មនុញ្ញ ចែងយ៉ាងលម្អិតពីអំណាចរបស់ព្រះមហាក្សត្រ (ជំពូកទី២) ហើយក៏បានចែងថា ពលរដ្ឋខ្មែរគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយមិនគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈក្នុងសង្គម ទ្រព្យសម្បត្តិ និងលក្ខខណ្ឌផ្សេងៗទៀត (ជំពូកទី៣) ។ រដ្ឋធម្មនុញ្ញ ក៏កំណត់យ៉ាងច្បាស់ពីការបែងចែកអំណាច រវាងស្ថាប័នទាំងបី ។ ស្ថាប័នទាំងបីមានអំណាចដាច់ដោយឡែកពីគ្នា ប៉ុន្តែមុខងាររបស់ស្ថាប័នទាំងបីនេះ មានទំនាក់ទំនងជាមួយគ្នាដោយផ្អែកលើកិច្ចសហប្រតិបត្តិការ និងការជំរុញឲ្យមានប្រព័ន្ធសម្រាប់ការត្រួតពិនិត្យ និងការធ្វើឲ្យមានតុល្យភាពអំណាចដូចមានចែងក្នុង(ជំពូកទី៤) ដើម្បីឲ្យស្ថាប័នទាំងបីនេះបានប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព ។ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ទទួលខុសត្រូវចំពោះការបកស្រាយធម្មនុញ្ញភាពនៃរដ្ឋធម្មនុញ្ញ និងដោះស្រាយវិវាទនានាដែលទាក់ទងទៅនឹងការបោះឆ្នោត។[30]

ដូចគ្នានឹងរបបរាជានិយមនៅចក្រភពអង់គ្លេស ព្រះមហាក្សត្រកម្ពុជាគឺជាព្រះប្រមុខរដ្ឋដែលតួនាទីទូលំទូលាយជានិមិត្តរូបដោយផ្អែកលើប្រពៃណីវប្បធម៌ខ្មែរ ដែលមានអាយុកាលជាង ពីរពាន់ឆ្នាំមកហើយ ប៉ុន្តែព្រះអង្គមិនមានអំណាចផ្នែកនយោបាយឡើយ។ ទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនកាន់អំណាច។ ចំណែកឯនាយករដ្ឋមន្ត្រីគឺជាអ្នកដឹកនាំការងារនីតិប្រតិបត្តិ។ រដ្ឋធម្មនុញ្ញនេះ បង្កើតប្រព័ន្ធសភានិយមពាក់កណ្ដាល ដែលតម្រូវឲ្យរាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភា។ រដ្ឋសភាអាចដកហូតតំណែងសមាជិករាជរដ្ឋាភិបាល ឬរំលាយរដ្ឋាភិបាលទាំងមូលដោយការបោះឆ្នោត។ ទោះជាយ៉ាងណាក្ដី សភាមិនអាចបង្កហានិភ័យចំពោះរាជរដ្ឋាភិបាលឡើយ ដោយសារនាយករដ្ឋមន្ត្រីកម្ពុជាអាចស្នើសុំឲ្យព្រះមហាក្សត្រ រំលាយសភា ដូចនៅប្រទេសបារាំងដែរ។

ជាងនេះទៀត ខុសគ្នាពីនាយករដ្ឋមន្ត្រីរបស់ចក្រភពអង់គ្លេស នាយករដ្ឋមន្ត្រីកម្ពុជាមិនចាំបាច់ជ្រើសរើសរដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលចេញពីសមាជិកសភាដែលបានជាប់ឆ្នោតឡើយ។ នេះមានន័យថា ស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិមិនបានផ្សាភ្ជាប់ខ្លាំងជាមួយគ្នា ដូចនៅចក្រភពអង់គ្លេសឡើយ។

វិធីនៃការបង្កើតរដ្ឋាភិបាលនេះ ធ្វើឲ្យនឹកឃើញទៅដល់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៥៨ របស់បារាំងដែលបានកំណត់អំណាចរបស់សភា ជាពិសេសរដ្ឋសភាជាតិ។ ជាការពិតណាស់ក្នុងពេលនោះ រដ្ឋាភិបាលបារាំងពង្រឹងអំណាចរបស់ខ្លួន ដោយខ្លាចថាសភានឹងក្លាយជាសភាមួយដែលមានអំណាចផ្តាច់ការ ឬហៅថារបបសភានិយមផ្តាច់ការ ដែលបានកើតឡើងក្នុងរបបសាធារណរដ្ឋទី៣ និងទី៤របស់ប្រទេសបារាំង។ ជាងនេះទៀត វិធីសាស្ត្រក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាបង្ហាញថាទ្វិសភាកម្ពុជាគឺពិតជាស្រដៀងទៅនឹងប្រទេសបារាំង។ លើសពីនេះទៀត នាយករដ្ឋមន្ត្រីកម្ពុជាមានអំណាចច្រើនក្នុងការចេញបទបញ្ជាផ្សេងៗដូចគ្នានឹងប្រទេសបារាំងដែរ។ កម្ពុជាអាចនិយាយបានថាជាប្រទេសដែលជារដ្ឋទោល (unitary State) ដូចប្រទេសបារាំង ប៉ុន្តែខុសគ្នាពី អាមេរិកដែលមានរចនាសម្ព័ន្ធសហព័ន្ធ។ លើសពីនេះទៀត សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតឲ្យកាន់តំណែង មិនមែនតាមរយៈការតែងតាំងពីព្រះមហាក្សត្រ ដោយកាន់តំណែងមួយជីវិតដូចនៅ ចក្រភពអង់គ្លេសឡើយ។ កម្ពុជាមានការតាក់តែងសរសេររដ្ឋធម្មនុញ្ញ ប្រព័ន្ធគ្រប់គ្រងរដ្ឋ និងជាពិសេសប្រព័ន្ធសភា ដែលមានភាពស្រដៀងគ្នានឹងប្រព័ន្ធដឹកនាំរដ្ឋរបស់បារាំង ជាជាងប្រព័ន្ធរបស់ចក្រភពអង់គ្លេស។

អំណាចនាយករដ្ឋមន្ត្រីកម្ពុជា មានភាពស្រដៀងនឹងប្រធានាធិបតីអាមេរិក ដោយសារនាយករដ្ឋមន្ត្រីកម្ពុជាជាអ្នកដឹកនាំ ឧបនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី ក្រសួងជំនាញ ស្ថាប័នឯករាជ្យ គណៈអភិបាល ក្រុមប្រឹក្សា និងគណៈកម្មាធិការ។

## *៥.១.៣ អំឡុងពេលនៃការពង្រឹងសភា*

កម្ពុជានៅតែបន្តអភិវឌ្ឍប្រជាធិបតេយ្យរបស់ខ្លួន ប៉ុន្តែតុល្យភាពនៃការបែងចែកអំណាចនៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ដោយហេតុថាស្ថាប័ននីតិប្រតិបត្តិនៅមិនទាន់មានការពិនិត្យតាមដានយ៉ាងគៀកកិតពីស្ថាប័នដទៃពីរផ្សេងទៀត។[31] ជាការពិត ការអនុវត្តប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ និងការគោរពរដ្ឋធម្មនុញ្ញកម្ពុជា ទើបប្រព្រឹត្តិទៅបានជាង ២៥ឆ្នាំប៉ុណ្ណោះ និងប្រហែលជាតម្រូវឲ្យចំណាយពេលបន្ថែមច្រើនជាងនេះទៀតដើម្បីបង្កើតឲ្យបាននូវតុល្យភាពអំណាច៖ ដោយសារប្រទេសកម្ពុជាធ្លាប់មានប្រវត្តិសាស្ត្រយ៉ាងធ្ងន់ធ្ងរទាក់ទងនឹងការប្រើប្រាស់អំពើហិង្សា ការសម្លាប់រង្គាល និងមិនមានបទពិសោធន៍ទាក់ទងនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដូច្នេះកម្ពុជាមិនអាចប្រែក្លាយអ្វីៗទាំងអស់តែមួយថ្ងៃ ឡើយ។ ជាងនេះទៀត សូម្បីតែប្រទេសជាច្រើនដែលបានចំណាយពេលរាប់រយឆ្នាំក្នុងការធ្វើឲ្យមានតុល្យភាពអំណាច (រួមទាំងចក្រភពអង់គ្លេស) ក៏តុល្យភាពនៃអំណាចនៅតែមានការ ប្រែប្រួលមិនឈប់ឈរ។[32] ទោះជាយ៉ាងណា ផ្នែកទី ៥.២ (ខាងក្រោម) បង្ហាញថាសភាកម្ពុជាបានបង្កើតនីតិ

វិធីជាច្រើនដើម្បីបំពេញមុខងារទាំង៣របស់ខ្លួន។ ចំណែកឯផ្នែកទី ៦ បង្ហាញពីដំណើរការសភាដើម្បីឆ្ពោះទៅរកភាពរីកចម្រើន។

### *៥.១.៤ ស្ថាប័នទាំងបីរបស់រដ្ឋ*[33]

### *៥.១.៤.១. ស្ថាប័ននីតិប្រតិបត្តិ*

រដ្ឋធម្មនុញ្ញកម្ពុជា ផ្តល់អំណាចនីតិប្រតិបត្តិទៅឲ្យ "រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា" ។ ដំណើរការនៃការតែងតាំងសមាជិករាជរដ្ឋាភិបាល ធ្វើឡើងតាមយន្តការមួយដែលត្រូវបំពេញតាមតម្រូវការនៃរបបសភានិយម។ ស្ថាប័ននីតិប្រតិបត្តិកម្ពុជាត្រូវបង្កើតឡើងដោយគណបក្សដែលឈ្នះចំនួនអាសនៈច្រើនជាងគេ នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររៀងរាល់ប្រាំឆ្នាំម្តង។ ដូចនៅក្នុងប្រព័ន្ធរបស់ចក្រភពអង់គ្លេស នាយករដ្ឋមន្ត្រីគឺជាសមាជិករដ្ឋសភា ដែលត្រូវតែងតាំងដោយព្រះមហាក្សត្រតាមសំណើរបស់ប្រធាន និងអនុប្រធានរដ្ឋសភា (ដែលត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតដោយសមាជិករដ្ឋសភា)។ នាយករដ្ឋមន្ត្រីជាអ្នកតែងតាំងសមាសភាពគណៈរដ្ឋមន្ត្រី(សមាជិកនៃគណៈរដ្ឋមន្ត្រីនេះអាចជា ឬមិនមែនជាសមាជិករដ្ឋសភា)។

រដ្ឋធម្មនុញ្ញតម្រូវឲ្យរាជរដ្ឋាភិបាលមានមុខងារពង្រឹង និងការពារឯករាជ្យជាតិ អធិបតេយ្យភាពជាតិ និងបូរណភាពដែនដី ហើយក៏តម្រូវឲ្យរាជរដ្ឋាភិបាលអនុម័តនូវគោលនយោបាយបង្រួបបង្រួមជាតិដើម្បី ជានា និងពង្រឹងសាមគ្គីភាពជាតិ ក្រមសីលធម៌ និងទំនៀមទម្លាប់ខ្មែរ។ លើសពីនេះទៅទៀត រដ្ឋធម្មនុញ្ញក៏តម្រូវឲ្យរាជរដ្ឋាភិបាលរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខ ព្រមទាំងការជំរុញអនុវត្តច្បាប់ផងដែរ។

នៅក្នុងឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលអះអាងយ៉ាងច្បាស់ និងដដែលៗ អំពីអាទិភាពរបស់ខ្លួន ក្នុងការការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពដែនដីនៃប្រទេសកម្ពុជា ដែលធ្លាប់ជួបប្រទះនូវវិបត្តិសង្គ្រាមនិងជម្លោះរ៉ាំរ៉ៃ ក៏ដូចជាបញ្ហាទាក់ទងនឹងទីតាំងភូមិសាស្ត្រនយោបាយសម្រាប់ប្រទេសកម្ពុជា។

រដ្ឋាភិបាលមានបេសកកម្មអនុវត្តគោលនយោបាយផ្សះផ្សាជាតិ ដើម្បីលុបបំបាត់ជម្លោះ និងវិបត្តិនយោបាយ ដែលបានរារាំងដល់ការអភិវឌ្ឍប្រទេស អស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ។

បន្ថែមទៅលើអំណាចរបស់រាជរដ្ឋាភិបាល ដែលរដ្ឋធម្មនុញ្ញបានកំណត់ឲ្យស្រាប់ដូចបានបកស្រាយខាងលើ ស្ថាប័ននីតិប្បញ្ញត្តិកម្ពុជា ក៏បានរួមចំណែកក្នុងការបង្កើនអំណាចដល់ស្ថាប័ននីតិប្រតិបត្តិតាមរយៈការបង្កើតឲ្យមានអាជ្ញាធររដ្ឋបាលដែលមានអំណាចក្នុងការចេញបទបញ្ញាផ្សេងៗ។ អាជ្ញាធរទាំងនេះមានដូចជា៖

- អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ (ឬដែលអាចហៅថាអាជ្ញាធរអប្សរា) នៅក្នុងខេត្តសៀមរាប
- គណៈកម្មការមូលបត្រកម្ពុជា
- អង្គភាពប្រឆាំងអំពើពុករលួយ

- អាជ្ញាធរអគ្គិសនីកម្ពុជា
- និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា។

អាជ្ញាធរ ឬគណៈកម្មការទាំងនេះនៅក្រោមការត្រួតពិនិត្យពីស្ថាប័នរដ្ឋណាមួយ ហើយចំណែកឯអាជ្ញាធរគណៈ កម្មការផ្សេងទៀតអាចមានមុខងារ ឧស្សាហកម្ម និងពាណិជ្ជកម្ម។

## *៥.១.៤.២ ស្ថាប័ននីតិប្បញ្ញត្តិ*

កម្ពុជាមានរបបទ្វីសភា (ក្នុងចំណោមរបបទ្វីសភាចំនួន ៧៥ ទូទាំងពិភពលោក[2])។ របបសភានេះ មានព្រឹទ្ធសភា និងរដ្ឋសភាដែលជាមួយគ្នាជាស្ថាប័ននីតិប្បញ្ញត្តិ។

រដ្ឋធម្មនុញ្ញកំណត់ចំនួនសមាជិករដ្ឋសភា យ៉ាងហោចណាស់ ១២០រូប។ សមាសភាពនៃរដ្ឋសភាទាំងមូលតម្រូវឲ្យមានការជ្រើសតាំងរៀងរាល់ ៥ ឆ្នាំម្តង។ ការបោះឆ្នោតនេះ គឺមានលក្ខណៈសកល សេរី ស្មើភាព ដោយផ្ទាល់ និងសម្ងាត់។ បច្ចុប្បន្នមានសមាជិករដ្ឋសភា ១២៣រូប ដែលត្រូវបានជ្រើសតាំងតាមប្រព័ន្ធតំណាងសមាមាត្របញ្ជីគណបក្ស៖ ពលរដ្ឋកម្ពុជាគ្រប់រូបដែលមានអាយុ ១៨ ឆ្នាំឡើង មានសិទ្ធិបោះឆ្នោត។ សមាជិកសភាទទួលខុសត្រូវចំពោះការពិភាក្សាផ្តល់មតិ អនុម័តច្បាប់ ដែលបានស្នើ ឬព្រាងដោយរាជរដ្ឋាភិបាល ឬដោយសមាជិកសភា។ រដ្ឋធម្មនុញ្ញចែងថា មិនអនុញ្ញាតឲ្យបេក្ខភាពសម្រាប់ធ្វើជាសមាជិករដ្ឋសភាជាសមាជិកនៃស្ថាប័នអំណាចផ្សេងឡើយ (លុះត្រាតែពួកគេត្រូវបានទាមទារឲ្យបម្រើនៅក្នុងស្ថាប័ននីតិប្រតិបត្តិ)។ នេះគឺជាការបញ្ចៀសនូវជម្លោះទាក់ទងនឹងផលប្រយោជន៍។ ប្រធានរដ្ឋសភាជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលមានសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសព្រះមហាក្សត្រ និងមានសិទ្ធិស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការពិនិត្យទៅលើធម្មនុញ្ញភាព (ប្រធានរដ្ឋសភាអាចផ្ញើច្បាប់ដែលបានអនុម័តដោយរដ្ឋសភាទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុនពេលប្រកាសឲ្យប្រើប្រាស់ ឬអាចស្នើឲ្យ ក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់រួចហើយ)។

រដ្ឋធម្មនុញ្ញ កំណត់ចំនួនសមាជិកព្រឹទ្ធសភា ដោយមិនឲ្យលើសពីពាក់កណ្តាលនៃចំនួនសរុបរបស់សមាជិករដ្ឋសភាឡើយ។ អាណត្តិព្រឹទ្ធសភាមានរយៈពេល ៦ឆ្នាំ ហើយបច្ចុប្បន្ន មានសមាជិក ៦១ រូប៖ ពីររូបតែងតាំងដោយព្រះមហាក្សត្រ ពីររូបទៀតត្រូវបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា និងក្រៅពីនេះ គឺត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រ។ព្រឹទ្ធសភាពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលបានអនុម័តដោយរដ្ឋសភាជាលើកដំបូង និងលើបញ្ហាទាំងពួងដែលរដ្ឋសភាដាក់ឲ្យពិនិត្យ។ ព្រឹទ្ធសភាអាចផ្ញើអនុសាសន៍ត្រឡប់ទៅរដ្ឋសភាជាតិវិញសម្រាប់ពិចារណា ប៉ុន្តែព្រឹទ្ធសភាមិនអាចបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឡើយ។រវាងសភាទាំងពីរ រដ្ឋសភាជាអ្នកសម្រេចចុងក្រោយ ។ ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល ដែលនេះជាតួនាទីនយោបាយដ៏ខ្ពង់ខ្ពស់របស់ព្រឹទ្ធសភា។ ប្រធានព្រឹទ្ធសភា ជាឥស្សរជនទី១ដែលត្រូវទទួលនាទីជាប្រមុខរដ្ឋស្តីទី នៅពេលមិនមានព្រះរាជវត្តមានរបស់

ព្រះមហាក្សត្រ ក្នុងនាមព្រះរាជានុសិទ្ធិ។ ប្រធានព្រឹទ្ធសភា ក៏ជាសមាជិកក្រុមប្រឹក្សារាជសម្បត្តិដែរ។ ព្រះមហាក្សត្រត្រូវការការយល់ព្រមពីប្រធានព្រឹទ្ធសភាក្នុងការដាក់ប្រទេសជាតិបិតក្នុងភាពអាសន្ន នៅពេលដែលប្រទេសជួបគ្រោះថ្នាក់។ ទន្ទឹមនេះ ប្រធានព្រឹទ្ធសភាជាប្រធានសមាជសភា។

សមាជិកសភាទាំងពីរ មានអភ័យឯកសិទ្ធិក្នុងការសម្តែងមតិក្នុងកាតព្វកិច្ចរបស់ពួកគេ។ អភ័យឯកសិទ្ធិអាចត្រូវបានបដិសេធ តាមរយៈការប្រជុំសភា។ ទោះជាយ៉ាងណា អភ័យឯកសិទ្ធិនេះ មិនអាចប្រើប្រាស់ក្នុងករណីបទល្មើសជាក់ស្តែងឡើយ។

សរុបមកកម្ពុជាមានសមាជិកសភា១៨៤រូប ខុសឆ្ងាយពីប្រទេសចិនដែលសមាជិកសភា មានរហូតដល់៣០០០រូប។ សមាជិកសភាកម្ពុជា ក៏មានចំនួនតិចជាងសមាជិកសភានៅទូទាំងពិភពលោកដែលជាមធ្យមមានចំនួន ២៤៥ រូប។ ចំណែកឯ តំបន់អាស៊ីប៉ាស៊ីហ្វិកវិញមានសមាជិកសភាជាមធ្យមគឺ ៣២៥រូប ។ [2] ជាមធ្យមអាចនិយាយថា នៅកម្ពុជា សមាជិកសភា១រូប តំណាងឲ្យប្រជាជន ៨៦,០០០ នាក់។ នេះគឺប្រសើរជាងប្រទេសផ្សេងៗជាច្រើនដោយហេតុថា មធ្យមភាគនៅលក្ខណៈសកលវិញស្មើនឹង១៤៦.០០០នាក់។

គួរកត់សម្គាល់ផងដែរថា ប្រមុខរដ្ឋាភិបាលក៏អាចផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់បានដែរ មិនមែនតែសមាជិកសភាទេ។ ជាការពិត នេះជាការអនុញ្ញាតឱ្យស្ថាប័ននីតិប្រតិបត្តិមានអំណាចនៅក្នុងការងារដែលតម្រូវឲ្យបំពេញដោយស្ថាប័ននីតិប្បញ្ញត្តិ ដោយហេតុថា ច្បាប់ជាច្រើនត្រូវបានអនុម័ត ឬកែប្រែតាមការផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រី។

### *៥.១.៤.៣ ស្ថាប័នតុលាការ*

ស្ថាប័នតុលាការ អនុវត្ត និងបកស្រាយច្បាប់ ដែលបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ។ ស្ថាប័នតុលាការ មានតុលាការកំពូល សាលាឧទ្ធរណ៍ សាលាដំបូងរាជធានីខេត្ត តុលាការយោធា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

យោងតាមរដ្ឋធម្មនុញ្ញ ស្ថាប័នតុលាការមានការទទួលខុសត្រូវដោះស្រាយជម្លោះទាំងអស់រួមទាំងវិវាទរដ្ឋបាល។ សាលាដំបូង គឺជាតុលាការជាន់ទាបថ្នាក់ខេត្ត និងរាជធានីភ្នំពេញ។ សាលាដំបូងនេះមានយុត្តាធិការទាក់ទងនឹងបញ្ហាទំនាស់ទាំងអស់ (នៅក្នុងបញ្ហារដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម ការងារ និងរដ្ឋបាល) ។ នៅក្រោមគោលការណ៍កម្រិតយុត្តាធិការទ្វេ (សិទ្ធិក្នុងការប្តឹងទៅតុលាការជាន់ខ្ពស់ជាងមុន) ពលរដ្ឋអាចប្តឹងបន្តទៅសាលាឧទ្ធរណ៍ ប្រសិនបើមិនមានការពេញចិត្តចំពោះការវិនិច្ឆ័យរបស់សាលាដំបូង។ថ្នាក់មធ្យមមានសាលាឧទ្ធរណ៍ និងតុលាការកំពូលដែលជាយុត្តាធិការខ្ពស់បំផុតនៅក្នុងប្រទេស។ ទីស្នាក់ការកណ្តាលរបស់តុលាការនេះគឺនៅរាជធានីភ្នំពេញ។

យុត្តាធិការនៅគ្រប់កម្រិតតុលាការមានសមត្ថកិច្ចក្នុងការដោះស្រាយជម្លោះទាំងអស់ លើកលែងតែមានតម្រូវការតាមផ្លូវច្បាប់ក្នុងការផ្ទេរយុត្តាធិការ ទៅឲ្យតុលាការពិសេសណាមួយ។ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងសាលាឧទ្ធរណ៍ (ជាភាសាបារាំងហៅថា "juridictions du fond")មានសមត្ថកិច្ចទាំងទៅលើអង្គច្បាប់ និងទៅលើអង្គហេតុ ដូចជានៅប្រទេសបារាំង។ តុលាការកំពូលមិនមែនជាថ្នាក់ទី៣នៃ

យុត្តាធិការរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ទេ ពីព្រោះតុលាការកំពូលមិនមានសមត្ថកិច្ចទៅលើអង្គហេតុទេ លើកលែងតែនៅក្នុងករណីពិសេស។ តុលាការកំពូលគឺជាយុត្តាធិការដែលមានសមត្ថកិច្ចទៅអង្គច្បាប់តែប៉ុណ្ណោះ។

បច្ចុប្បន្ននេះមានយុត្តាធិការពិសេសមួយចំនួន (exceptional jurisdiction) ដែលបានបង្កើតឡើង ដើម្បីមានសមត្ថកិច្ចទៅលើតម្រូវការចាំបាច់កំណត់ដោយច្បាប់ ឬដោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ជាឧទាហរណ៍ ច្បាប់ចុះថ្ងៃទី ៨ ខែកុម្ភៈឆ្នាំ ១៩៩៣ បានបង្កើតឲ្យមានតុលាការយោធាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការពារជាតិ។ ជាឧទាហរណ៍ផងដែរ ក្នុងឆ្នាំ ២០០១ សភាកម្ពុជា បានអនុម័តច្បាប់បង្កើតតុលាការពិសេសដើម្បីកាត់ទោសបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬអ.វ.ត.ក.។ លើសពីនេះទៀត រដ្ឋធម្មនុញ្ញបានផ្តល់តួនាទីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រុមប្រឹក្សាធម្មនុញ្ញមានយុត្តាធិការទៅលើបញ្ហាវិវាទកម្មទាក់ទងនឹងការបោះឆ្នោត។

## *៥.២ តើសភាកម្ពុជាបំពេញមុខងារទាំងបីដោយរបៀបណា?*

### *៥.២.១ មុខងារតំណាង*

មាត្រា ៧៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងឲ្យប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ តួនាទីតំណាងនេះតម្រូវឲ្យសមាជិករដ្ឋសភា ធ្វើការប្រមូលទស្សនៈ និងកង្វល់របស់ប្រជាជន ហើយនាំយកមកកាន់រដ្ឋសភាជាតិ សម្រាប់ការជជែកពិភាក្សា ដើម្បីរកដំណោះស្រាយ ឬធ្វើសកម្មភាពបន្ថែមទៀត។ ព្រឹទ្ធសភាមានការទទួលខុសត្រូវដោយផ្ទាល់ ក្នុងភាពជាអ្នកតំណាងឲ្យក្រុមប្រឹក្សាឃុំ / សង្កាត់ ក្នុងភូមិភាគ ព្រមទាំងប្រជាជាតិខ្មែរទាំងមូល។ យន្តការភាគច្រើនដែលសមាជិកសភាប្រើប្រាស់ដើម្បីទាក់ទងជាមួយនឹងប្រជាពលរដ្ឋ គឺការរៀបចំសិក្ខាសាលា ការពិគ្រោះយោបល់ជាសាធារណៈ និងការរៀបចំវេទិកា។ នៅក្នុងព្រឹត្តិការណ៍ទាំងនេះ សមាជិកសភាផ្សព្វផ្សាយព័ត៌មានច្បាប់ និងជំរុញលើកទឹកចិត្តឲ្យប្រជាពលរដ្ឋបញ្ចេញនូវទស្សនៈ យោបល់ និងការយល់ឃើញរបស់ពួកគេ។ ការចុះបេសកកម្ម ការស្តាប់អ្នកជំនាញធ្វើការបកស្រាយ និងបេសកកម្មក្រៅប្រទេស ជួយឲ្យសមាជិកសភា ទទួលបាននូវព័ត៌មាន និងរួមចំណែកដល់ការពិភាក្សានៅថ្នាក់មូលដ្ឋាន តំបន់ ឬអន្តរជាតិ។ ដើម្បីជួយឲ្យសភាដោះស្រាយបញ្ហាឲ្យកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀត រដ្ឋសភា និងព្រឹទ្ធសភា បង្កើតក្រុមការងារ និងគណៈកម្មការដែលផ្តោតលើការងារជាក់លាក់ជាច្រើន ទាំងនៅក្នុងប្រទេស និងនៅបរទេស។ ភាពរីកចម្រើនរបស់សភាក្នុងការប្រើប្រាស់គេហទំព័រនិងបណ្តាញសង្គម ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយជាតិ និងតំបន់ ធ្វើឲ្យទំនាក់ទំនងរវាងសភា និងប្រជាជនកម្ពុជាកាន់តែមានភាពស៊ីជម្រៅ។

### ៥.២.២ មុខងារនីតិកម្ម

សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ ដំបូងត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាល ឬសភា ហើយបន្ទាប់មកត្រូវពិនិត្យដោយក្រុមការងារផ្នែកច្បាប់ និងគណៈកម្មការអន្តរក្រសួងមុនពេលបញ្ជូនទៅឲ្យទីស្តីការគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាង ត្រូវបញ្ជូនបន្តទៅកាន់ រដ្ឋសភាជាតិដើម្បីកែសម្រួល។ ដំណាក់កាលបន្ទាប់គឺការពិនិត្យ និងផ្ទេរទៅវិញទៅមករវាងរដ្ឋសភា និងព្រឹទ្ធសភា ចំពោះសេចក្តីព្រាងច្បាប់ រួមនឹងការពិភាក្សាយោបល់ចំពោះខ្លឹមសារនៃសេចក្តីព្រាងនេះ ដើម្បីធានាថាសេចក្តីព្រាងច្បាប់នេះមានគោលដៅច្បាស់លាស់ ប្រកបដោយសមធម៌ និងប្រសិទ្ធភាព មុននឹងឈានដល់ការសម្រេចចុងក្រោយ។ នៅពេលជាមួយគ្នានេះ ក្រុមប្រឹក្សាធម្មនុញ្ញនឹងត្រូវបានស្នើឲ្យពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់ (ច្បាប់រៀបចំអង្គការ) ដើម្បីកុំឲ្យមានភាពប្រាសចាកណាមួយពីរដ្ឋធម្មនុញ្ញ។ ចុងបញ្ចប់ សេចក្តីព្រាងត្រូវឡាយ ព្រះហត្ថលេខាដោយ ព្រះមហាក្សត្រ ហើយបន្ទាប់មកប្រកាសឲ្យប្រើប្រាស់។ សភា ក៏អាចអនុម័តយល់ព្រម ឬលុបចោល សន្ធិសញ្ញា និងអនុសញ្ញាផងដែរ។

### ៥.២.៣ មុខងារត្រួតពិនិត្យ

បន្ថែមលើការត្រួតពិនិត្យទៅលើការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ សភាមានកាតព្វកិច្ចលើកជាសំណួរទៅកាន់ស្ថាប័ននីតិប្រតិបត្តិ និងកោះអញ្ជើញរដ្ឋមន្ត្រីណាមួយឲ្យមកបំភ្លឺបញ្ហានានាក្នុងវិស័យជំនាញរបស់ក្រសួង។ សមាជិកសភារក្សាការពិនិត្យតាមដាន ការអនុវត្តរបស់រាជរដ្ឋាភិបាល និងអញ្ជើញមន្ត្រីជាន់ខ្ពស់ឲ្យជួយពន្យល់បញ្ជាក់ពីបញ្ហាពាក់ព័ន្ធ។ នេះគឺបង្ហាញពីភាពទទួលខុសត្រូវរបស់អំណាចនីតិប្រតិបត្តិចំពោះសមាជិកសភា។

### ៥.២.៤ លក្ខខណ្ឌ និងមុខងាររបស់គណៈកម្មការ និងក្រុមផ្សេងទៀត

មុនឆ្នាំ ១៩៩៩ កម្ពុជាបានប្រកាន់យករបបសភាឯក ប៉ុន្តែតាមរយៈវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៩ សភាកម្ពុជាបានប្រកាន់យករបបទ្វីសភាឡើងវិញ។[34] ការធ្វើវិសោធនកម្មនេះជាលទ្ធផលនៃកិច្ចព្រមព្រៀងរវាងគណបក្សសំខាន់ពីរគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច (FUNCIPEC) បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៨។ ជាមួយគ្នានេះផងដែរ ព្រឹទ្ធសភាកម្ពុជាត្រូវបានបង្កើតឡើងជាសភាជាន់ខ្ពស់ ដើម្បីសម្របសម្រួលការងាររវាងស្ថាប័ននីតិប្រតិបត្តិ និងរដ្ឋសភា។ មុនការបោះឆ្នោតជាតិឆ្នាំ២០១៣ ទាំងព្រឹទ្ធសភា និងរដ្ឋសភាមានគណៈកម្មការជំនាញចំនួនប្រាំបួនប៉ុណ្ណោះ។[35] បន្ទាប់មក (នីតិកាលទី៥នៃរដ្ឋសភា និងនីតិកាលទី៣នៃព្រឹទ្ធសភា) ដោយមានកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរវាងគណបក្ស គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណៈកម្មការទី១០ ត្រូវបានបង្កើតឡើង ដោយមានឈ្មោះថា គណៈកម្មការ អង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ។ ដូច្នេះ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងរដ្ឋសភាត្រូវបានធ្វើវិសោធនកម្មឡើងវិញដើម្បីបញ្ចូលគណៈកម្មការទី១០។ គណៈកម្មការជំនាញទាំង១០ មានដូចជា[36]:

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន
- គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍
- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី
- គណៈកម្មការសារធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- គណៈកម្មការ អង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ[36]

លើសពីនេះទៅទៀត បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និងរដ្ឋសភាកំណត់ឲ្យមានគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាយន្តការមួយដ៏សំខាន់ រួមមានសមាសភាព ដូចជាប្រធានសភា អនុប្រធានទីមួយ អនុប្រធានទីពីរ និងប្រធានគណៈកម្មការទាំងអស់របស់សភា។ គណៈកម្មាធិការអចិន្ត្រៃយ៍ មានកាតព្វកិច្ច គាំទ្រដំណើរការសភា ជាពិសេសការរៀបចំប្រជុំ មានដូចជាកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញសភាសាមញ្ញ និងវិសាមញ្ញ។[36] ក្រៅពីគណៈកម្មការនានា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងនីតិកាលទី៣ព្រឹទ្ធសភាបង្កើតឲ្យមានក្រុមសមាជិកព្រឹទ្ធសភា ក្រុមសភាជិកសភាប្រចាំភូមិភាគ សមាជិកព្រឹទ្ធសភាដើម្បីសម្រួលដល់ដំណើរការរបស់ព្រឹទ្ធសភា និងផ្សាភ្ជាប់ទំនាក់ទំនងដើម្បីឲ្យបានជិតស្និតជាមួយម្ចាស់ឆ្នោត (ក្រុមប្រឹក្សាឃុំ សង្កាត់) និងប្រជាពលរដ្ឋនៅក្នុងភូមិភាគ[37] ចំណែកឯសមាជិករដ្ឋសភាវិញ ដើរតួនាទីជាអ្នកតំណាងរបស់ប្រជាពលរដ្ឋទាំងមូល។[38] ទន្ទឹមនឹងនេះ ព្រឹទ្ធសភា បង្កើតឲ្យមាន ក្រុមមិត្តភាពទ្វេរភាគី ជាមួយប្រទេសនានា និងក្រុមការងារអន្តរជាតិពហុភាគី ជាមួយអង្គការសភាផ្សេងទៀត ដែលមានដូចខាងក្រោម៖

**ក្រុមមិត្តភាពទ្វេរភាគី៖**

- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាជប៉ុន
- ក្រុមមិត្តភាពទ្វេរភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនៃសាធារណរដ្ឋបារាំង
- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសាធារណរដ្ឋសង្គមនិយមវៀតណាម

- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាក្រុមប្រឹក្សានយោបាយចិន
- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសហព័ន្ធមីយ៉ាន់ម៉ា
- ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាអូស្ត្រាលី និងញូហ្សីឡែន
- ក្រុមមិត្តភាពទ្វេភាគី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាព្រះរាជាណាចក្រថៃឡង់ដ៍
- ក្រុមមិត្តភាពទ្វេភាគី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយបែលហ្សិក
- ក្រុមមិត្តភាពទ្វេភាគី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយតួកគី
- ក្រុមមិត្តភាពទ្វេភាគី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមប្រឹក្សាសហព័ន្ធនៃសភាសហព័ន្ធនៃសហព័ន្ធរុស្ស៊ី
- ក្រុមមិត្តភាពទ្វេភាគី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាម៉ុងហ្គោលី

**ក្រុមមិត្តភាពពហុភាគី៖**

- ក្រុមសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកកិច្ចការសភានិយាយភាសាបារាំង (APF)
- បណ្តាញសមាជិកព្រឹទ្ធសភា ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺរបេង និងគ្រុនចាញ់
- ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការអន្តរសភាអាស៊ាន (AIPA)
- ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការសហភាពអន្តរសភា (IPU)
- និងក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចការអន្តរសភាកម្ពុជា ឡាវ វៀតណាម ដើម្បីជំរុញ និងតាមដានការអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍តំបន់ត្រីកោណ។

## ៦. ការអភិវឌ្ឍសភាក្នុងប្រទេសកម្ពុជា

### *៦.១. តើសភាកម្ពុជាមានរបៀបការងារយ៉ាងដូចម្តេច ដើម្បីទទួលបានប្រសិទ្ធភាព?*

របាយការណ៍សភាជាសកល (the Global Parliamentary Report)[2] បានបញ្ជាក់ថាស្ទើរតែគ្រប់សភាទាំងអស់ ទទួលស្គាល់ពីភាពចាំបាច់ក្នុងការលើកកម្ពស់ការយល់ដឹង និងចំណាប់អារម្មណ៍របស់សាធារណជន ចំពោះការងារសភា ហើយសភាជាច្រើន បានអនុវត្តគម្រោង និងការអភិវឌ្ឍសមត្ថភាព ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ។

### *៦.២. ទំនាក់ទំនងរវាងប្រព័ន្ធផ្សព្វផ្សាយ និងព្រឹទ្ធសភា*

ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា មានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ចាប់តាំងពីការបញ្ចប់នៃរបបខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧៩ និងសាធារណរដ្ឋប្រជាមានិតកម្ពុជានៅប្រហែលក្នុងឆ្នាំ១៩៩០។[39] នៅត្រឹមឆ្នាំ២០១៦ ប្រហែលពាក់កណ្តាលនៃប្រជាជនកម្ពុជាបានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត សម្រាប់អានព័ត៌មាន (៧៣ ភាគរយ) ការប្រើប្រាស់បណ្តាញសង្គមហ្វេសប៊ុក (៦៣ ភាគរយ) ការចូលទៅកាន់គេហទំព័រផ្សេងៗ (៤២ ភាគរយ)។[40] ឧបករណ៍ទាំងនេះ ផ្តល់នូវភាពងាយស្រួល និងឆាប់រហ័ស និង

មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការផ្សព្វផ្សាយព័ត៌មាននៅទូទាំងប្រទេស។ ឧទាហរណ៍ ក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ជាតិ នៅក្នុងឆ្នាំ២០១៣ ការជ្រៀតចូលនៃប្រព័ន្ធបណ្តាញសង្គម ជាពិសេសបណ្តាញសង្គមហ្វេសប៊ុក មានឥទ្ធិពលយ៉ាងខ្លាំងចំពោះនយោបាយ និងអ្នកបោះឆ្នោត។[41] ហេតុដូច្នេះ ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីយ៉ាងសំខាន់សម្រាប់ព្រឹទ្ធសភាកម្ពុជា។ ប្រព័ន្ធទាំងនេះជាឧបករណ៍ដែលអាចបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ព្រឹទ្ធសភា ប្រកបដោយតម្លាភាពចំពោះប្រជាពលរដ្ឋ។ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសភា និងសមាជិកសភា អាចផ្ញើសារយ៉ាងឆាប់រហ័សទៅកាន់សាធារណជន ជាពិសេសតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការប្រាស្រ័យទាក់ទង។ ប្រព័ន្ធបណ្តាញសង្គម គឺជាឧបករណ៍ដែលមានប្រសិទ្ធភាពសម្រាប់ទាំងប្រជាពលរដ្ឋ និងសមាជិកព្រឹទ្ធសភាក្នុងការផ្លាស់ប្តូរគំនិតនិងព័ត៌មានផ្សេងៗ។[42] ការផ្តល់ព័ត៌មានទៅកាន់សាធារណជន ត្រូវបានទទួលស្គាល់ជាការទទួលខុសត្រូវចម្បងរបស់ព្រឹទ្ធសភា។ ការណ៍នេះ ជំរុញឲ្យអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា បង្កើតឧបករណ៍សម្រាប់ផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាសម្រាប់ទាក់ទងជាមួយប្រជាពលរដ្ឋផងដែរ។ ឧបករណ៍ដែលព្រឹទ្ធសភាប្រើប្រាស់មានដូចខាងក្រោម៖

- ទំព័រហ្វេសប៊ុក៖ អ្នកនាំពាក្យព្រឹទ្ធសភា ព័ត៌មានសភា ប្រជាធិបតេយ្យ និងនីតិរដ្ឋ (Senate Spokesperson, Senate News, Democracy and Rule of Law)
- បណ្តាញ Twitter៖ អ្នកនាំពាក្យព្រឹទ្ធសភា (@spssenate)
- បណ្តាញYouTube៖ SPS Senate
- គេហទំព័រផ្លូវការរបស់ព្រឹទ្ធសភា៖ www.senate.gov.kh[42]
- កម្មវិធីទូរស័ព្ទដៃ ដែលហៅថា «ព័ត៌មានព្រឹទ្ធសភា» អាចប្រើប្រាស់ជាមួយប្រព័ន្ធប្រតិបត្តិការ Android ឬ IOS ដើម្បីតាមដានសកម្មភាពរបស់ព្រឹទ្ធសភា[43]
- ទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែ។

លើសពីនេះទៀត ក្នុងអំឡុងពេលកិច្ចប្រជុំរបស់ព្រឹទ្ធសភា អ្នកកាសែត ត្រូវបានទទួលការស្វាគមន៍។ ឧទាហរណ៍៖ នាយកដ្ឋានព័ត៌មាន ទទួលស្វាគមន៍អ្នកកាសែត នៅពេលដែលមានពិធីសំណេះសំណាលរវាងសមាជិកព្រឹទ្ធសភា និងភ្ញៀវជាតិ អន្តរជាតិ កិច្ចប្រជុំផ្សេងៗដូចជាកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ និងប្រជុំគណៈកម្មការជំនាញ។ អ្នកកាសែត ត្រូវបានទទួលស្វាគមន៍នៅក្នុងបន្ទប់មួយដែលបានរៀបចំដើម្បីឲ្យពួកគេអាចទស្សនាការប្រជុំពេញអង្គ។ សកម្មភាពក្នុងអំឡុងពេលសម័យប្រជុំពេញអង្គត្រូវបានផ្សាយបន្តផ្ទាល់ នៅលើកញ្ចក់ទូរទស្សន៍ និងវិទ្យុជាតិ។[42]

# គន្ថនិទ្ទេសក៍

[1] Watts, D. 2003. *Understanding US/UK Government and Politics.* Manchester University Press: Manchester. Pp305

[2] Power, G. 2012. *Global Parliamentary Report: The changing nature of parliamentary representation.* Inter-Parliamentary Union and United Nations Development Programme: Denmark. P2.

[3] Johnson, J.K. 2005. *The Role of Parliament in Government.* World Bank Institute: Washington. And Republic of Austria. (n.d.) *The Separation of Powers – Why is it Necessary?* Available at: https://www.parlament.gv.at/ENGL/PERK/PARL/POL/ParluGewaltenteilung/index.shtml [Accessed on: 4 January 2017].

[4] The UK Supreme Court has, for instance, been deciding whether or not the UK Prime Minister has the `constitutional' right to trigger Article 50, which starts the process through which the UK will leave the European Union, alone, without putting it to a full parliamentary vote. In the absence of a written Constitution, the Court's ruling will be decided more on `convention' and historical precedent

[5] World Public Opinion 2008. *World Publics Say Government Should Be More Responsive to the Will of the People.* Available at: http://worldpublicopinion.net/world-publics-say-governments-should-be-more-responsive-to-the-will-of-the-people/ [Accessed 10 January 2017]

[6] Parliamentary Institute of Cambodia. 2016. The Study Mission of the Cambodian Parliamentary Delegation to the Swiss Parliament. *PIC Parliamentary Review*. Issue 1, 2016. PIC: Phnom Penh. Pp5

[7] Yamamoto, H. 2007. *Tools for parliamentary oversight: A comparative study of 88 national parliaments.* Inter-Parliamentary Union: Geneva. And Williams, J.G. 2004. *The Role of Parliaments in Holding Government to Account and Controlling Corruption*. Global Organisation of Parliamentarians Against Corruption

[8] Beetham, D. 2006. *Parliament and Democracy in the Twenty-First Century: a guide to good practice.* Inter-Parliamentary Union: Geneva. P7

[9] Byock, J. 2002. The Icelandic Althing: Dawn of Parliamentary Democracy. In: *Heritage and Identity: Shaping the Nations of the North*, ed. J.M. Fladmark, pp1-18. The Heyerdahl Institute and Robert Gordon University. Donhead St. Mary, Shaftesbury: Donhead

[10] UK Parliament (n.d.). *Birth of the English Parliament.* Available at: http://www.parliament.uk/about/living-heritage/evolutionofparliament/originsofparliament/birthofparliament/. [Accessed on: 9 January 2017]

[11] UK Parliament. 2013. *The History of the Parliamentary Franchise.* Research Paper 13/14. House of Commons Library: London

[12] Economist Intelligence Unit. 2016. *Democracy Index 2015: Democracy in an age of anxiety.* EIU: London

[13] Chartsbin. (n.d.). *Systems of Government by Country.* Available at: http://chartsbin.com/view/6kx [Accessed on 4 January 2017]

[14] UK Parliament. (n.d.). *Parliament and the Government.* Available at shttps://www.parliament.uk/about/how/role/relations-with-other-institutions/parliament-government/ [Accessed 29 December 2016]

[15] US Government (n.d.). *Branches of Government.* Available at: www.usa.gov/branches-of-government [Accessed on: 4 January 2017]. And US Government. (n.d). *Structure of the United States Government.* Available at: http://www.theusegov.com/ [Accessed 4 January 2017]

[16] Wing, N. 22 December 2016. Final Popular Vote Total Shows Hillary Clinton Won Almost 3 Million More Ballots Than Donald Trump. *Huffington Post.* Available at: http://www.huffingtonpost.com/entry/hillary-clinton-popular-vote_us_58599647e4b0eb58648446c6 [Accessed 5 January 2017]

[17] US Electoral College National Archives and Records Administration. (n.d.). *What is the Electoral College?.* Available at http://www.archives.gov/federal-register/electoral-college/about.html [Accessed 5 January 2017]. And Bromwich, J.E. 8 November 2016. How Does the Electoral College Work? *New York Times.*Available at http://www.nytimes.com/2016/11/09/us/politics/how-does-the-electoral-college-work.html?_r=o [Accessed 5 January 2017]

[18] French Government. (n.d.). *How Government Works.* Av Available at: http://www.gouvernement.fr/en/how-government-works [Accessed 4 January 2017]. And Liu, E. 2000. *Systems of Government in Some Foreign Countries: France.* Research and Library Services Division, Legislative Council Secretariat: Hong Kong

[19] French National Assembly (Assemblée Nationale). (n.d.). Legal Texts. Available at: http://www2.assemblee-nationale.fr/langues/welcome-to-the-english-website-of-the-french-national-assembly [Accessed 12 January 2017]

[20] Liu, E. 2000. *Systems of Government in Some Foreign Countries: France.* Research and Library Services Division, Legislative Council Secretariat: Hong Kong

[21] ACE Electoral Knowledge Network (n.d.). *Electoral Systems.* Available at http://aceproject.org [Accessed 5 January, 2017]; Menocal, A.R. 2011. *Why electoral systems matter: an analysis of their incentives and effects on key areas of governance.* Overseas Development Institute: United Kingdom; Horowitz, D.L. (2003). Electoral Systems and their Goals: A Primer for Decision-Makers. In: *Journal of Democracy.* 14(4) October 2003, 115-127; Golder, M. 2004. Democratic electoral systems around the world, 1946-2000. *Electoral Studies 24 (2005) 103-121; and* Bormann, N.-C., and M. Golder. 2012. Democratic Electoral Systems around the world, 1946-2011. *Electoral Studies 32 (2013) 360-369*

[22] Information in this section is compiled from: Beetham, D. 2006. *Parliament and Democracy in the Twenty-First Century: a guide to good practice.* Inter-Parliamentary Union: Geneva. pp15; Moser, R.G. and E. Scheiner. 2004. Mixed electoral systems and electoral system effects: controlled comparison and cross-national analysis. In: *Electoral Studies.* 23(2004) 575-599; Norris, P. 1997. Choosing Electoral Systems: Proportional, Majoritarian and Mixed Systems. In: *International Political Science Review.* Vol 18(3) July 1997: 297-312; and The Week. 27 June 2016. *Proportional representation: The pros and cons.* Available at: http://www.theweek.co.uk/22271/proportional-representation-the-pros-and-cons. [Accessed 5 January 2017]

[23] Sithi.org. (n.d.). *Map of Female MPs Elected in the 2013 National Assembly Elections.* Available at: http//sithi.org/temp.php?url=election/nelection.php. [Accessed 10 January 2017]

[24] Waring M., G. Greenwood, C. Pintat, D. Meyer, K. Jabre, and O. Solera. 2000. *Politics: Women's Insight.* Inter-Parliamentary Union: New York. Pp128

[25] Caroline Hughes, "Understanding the Elections in Cambodia 2013", AGLOS: JOurnal of Area-Based Gloab Studies, 2015, pp. 1-2. Accessed on 27 April 2017: http://dept.sophia.ac.jp/g/gs/wp-content/uploads/2015/06/b98c8184d35f9b156df22f210dd322a2.pdf
[26] Croissant Aurel*, Electoral politics in Cambodia. Historical Trajectories, Current Challenges and Comparative Perspectives*, Konrad Adenauer Stiftung, Cambodia 2016, p. 17.
[27] Destination Justice. (n.d.). Cambodia: the electoral process. Available at http://destinationjustice.org/briefing-paper-election-process-in-cambodia/ [Accessed on: 12 January 2017]

[28] Holligan, J., and T. Abdulhak. 2011. *Overview of the Cambodian History, Governance and Legal Sources*. **Hauser Global Law School Program, New York University School of Law. Available at** http://www.nyulawglobal.org/globalex/Cambodia.html **[Accessed 2 January 2017]**

[29] Constitution of Cambodia. Available at: http://www.constitution.org/cons/cambodia.htm [Accessed 12 January 2017]

[30] Constitutional Council of Cambodia. (n.d.). *What is the Constitutional Council of Cambodia.* Available at: http://ccc.gov.kh/whatisccc_en.php [Accessed 6 January 2017]

[31] Bhagat, R. 2015. Separation of Powers without Checks and Balances in Cambodia. *Journal of Alternative Perspectives in the Social Sciences* (2015), 6(4), 389-401; and UNDP Cambodia. 2010. *Checks and Balances: Outcome Evaluation 2006-2009.* UNDP: Phnom Penh

[32] Benwell, R. and O. Gay. (n.d.) *The Separation of Powers.* Parliament and Constitution Centre, House of Commons Library: London

[33] Information for this section came from sources including Open Development Cambodia (https://opendevelopmentcambodia.net), the Cambodian Information Center (http://www.cambodia.org) and the websites of the Cambodian National Assembly and Senate (http://www.nac.org.kh/ and http://www.senate.gov.kh)

[34] Hor, P. Kong, P. and Menzel, J. (2016). *Cambodian Constitutional Law. Konrad Adenauer Stiftung.* P. 18. Available at http://www.pscljr.gov.kh/media/documents/Cambodia%20Constitutional%20Law_-234757791.pdf

[35] Cambodian Center for Human Rights. (2012). *Institutions Series: The Senate.* Available at http://cchrcambodia.org/admin/media/factsheet/factsheet/english/2012_01_27_CCHR_Factsheet_Institutions_The_Senate_ENG.pdf

[36] Cambodia. (2015). *Internal Rule of the Senate and the Inter Rule of the National Assembly.*

[37] Senate Secretariat. (2014). *Decision on the Nomination of the Senate Members.*

[38] Constitution of Cambodia, Article 77.

[39] Oldag, A. (2015). *Freedom of the Press and Media Regulation in Cambodia.* Konrad Adenauer Stiftung. P.4. Available at http://www.kas.de/wf/doc/kas_41221-544-1-30.pdf?150521041653

[40] UNDP. (2014). *Media Habits and information sources of YoutHin caMbodia.* Phnom Penh. Available at http://www.kh.undp.org/content/dam/cambodia/docs/DemoGov/Media%20Habits%20and%20Information%20Sources%20of%20Youth%20in%20Cambodia.pdf

[41] Soeung, S. (2013). Social Media's Growing Influence on Cambodian Politics. Washington. East-West Center. Available at http://www.eastwestcenter.org/sites/default/files/private/apb_222.pdf

[42] Minea, C. (2016). *Relations between Parliament and Media.* Parliamentary Institute of Cambodia.

[43] Nida, H. (2016). *Information and Communication Technologies in Parliaments: Situation and Perspective.* Parliamentary Institute of Cambodia.